ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា (អយក)

នាយកដ្ឋានធានាគុណភាពអប់រំ (ធគអ)

# ក្របខ័ណ្ឌការវាយតម្លៃការសិក្សារបស់សិស្ស

## កម្រិតមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ

ខែមិថុនា ឆ្នាំ ២០១៨

# មុខកថា

កំណែទម្រង់ស៊ីជម្រៅវិស័យអប់រំក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ សម្រេចបាននូវសមិទ្ធផលចម្បងៗជាច្រើន។ កំណែទម្រង់នេះបានចាប់ផ្តើមឡើងក្នុងកាលៈទេសៈដ៏សមស្រប និងមានសារសំខាន់ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់ប្រទេសដែលចង់ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ចក្ខុវិស័យខាងលើបានដើរតួនាទីជាស្នូលនៃស្ថិរភាពកំណើនសេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបានក្នុងទសវត្សរ៍ចុងក្រោយនេះ ហើយក៏ជាស្នូលនៃការបង្កើនឱកាសសម្រាប់វិស័យអប់រំផងដែរ។ តែទោះជាយ៉ាងនេះក្តី កិច្ចការដែលត្រូវបន្តអនុវត្តចំពោះមុខ គឺការកែលម្អគុណភាពសិក្សារបស់សិស្ស ដើម្បីឱ្យពួកគេមានចំណេះដឹង ជំនាញ និងសមត្ថភាពដើម្បីចូលរួមធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យរបស់ប្រទេស ព្រមទាំងអាចចូលរួមក្នុងបរិបទសង្គម និងសេដ្ឋកិច្ចសកលផងដែរ។ ការពង្រឹងការសិក្សា ក៏ដូចជាការលើកកម្ពស់ការវាយតម្លៃការសិក្សារបស់សិស្ស គឺជាយុទ្ធសាស្ត្រដើម្បីធានាថា សមិទ្ធផលសិក្សារបស់សិស្សនឹងឆ្លើយតបទៅនឹងលទ្ធផលសិក្សាដែលបានរំពឹងទុកទាំងសម្រាប់កម្រិតជាតិ និងអន្តរជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាផ្តល់នូវការអប់រំដ៏ប្រសើរបំផុត ព្រមទាំងប្រកបដោយភាពថ្លៃប្រឌិតសម្រាប់កុមារទាំងអស់។ សមិទ្ធផលមួយចំនួនដែលទទួលបានពីការខិតខំប្រឹងប្រែងនេះដូចជា ការបង្កើតសាលារៀនជំនាន់ថ្មី ការកែលម្អការគ្រប់គ្រងតាមសាលារៀន ការបង្កើនគុណវុឌ្ឍិ និងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងការពង្រឹងប្រព័ន្ធវង្វាយតម្លៃការសិក្សានៅកម្រិតថ្នាក់រៀន សាលារៀន ថ្នាក់ជាតិ តំបន់ និងអន្តរជាតិជាដើម សុទ្ធតែមានគោលដៅរួមចុងក្រោយ គឺធ្វើឱ្យសិស្សានុសិស្សអាចសម្រេចបាននូវសមិទ្ធផលសិក្សាគួរជាទីពេញចិត្ត ហើយស្របទៅនឹងទីផ្សារការងារ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការធ្វើវង្វាយតម្លៃការសិក្សា គឺជាមូលដ្ឋានស្នូលនៃគ្រប់អន្តរាគមន៍វិស័យអប់រំទាំងអស់។

ក្របខណ្ឌវង្វាយតម្លៃការសិក្សាកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនេះត្រូវបានបង្កើតឡើងដើម្បីធ្វើជាឯកសារណែនាំអំពីគោលការណ៍នៃការវាយតម្លៃការសិក្សា និងលទ្ធភាពធ្វើសុខដុមនីយកម្មនៃគ្រប់ប្រភេទវង្វាយតម្លៃការសិក្សាមានស្រាប់ដែលអាចជាន់គ្នា ឬមិនបានរៀបចំឱ្យបានត្រឹមត្រូវព្រមទាំងគូសបញ្ជាក់ពីអ្វីដែលចាំបាច់ត្រូវកត់សម្គាល់នៅក្នុងប្រព័ន្ធវង្វាយតម្លៃការសិក្សាក្នុងប្រទេសកម្ពុជា ដើម្បីជួយជំរុញឱ្យសិស្សរៀនសូត្រដោយផ្ទាល់ និងជួយតាមដំណាក់នៃការសិក្សារបស់សិស្ស។ ក្របខណ្ឌនេះ ក៏នឹងផ្តល់ជាមូលដ្ឋានគន្លឹះដ៏សំខាន់ដល់ស្ថាប័នពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការគាំទ្រ និងពិនិត្យតាមដានដំណើរការវង្វាយតម្លៃការសិក្សាផងដែរ។ វិធីសាស្ត្រនៃការប្រើប្រាស់លទ្ធផលវង្វាយតម្លៃការសិក្សាដើម្បីកែលម្អការបង្រៀន និងរៀនឱ្យកាន់តែប្រសើរឡើង ហើយប្រើប្រាស់ដោយអ្នកណាខ្លះ ក៏ត្រូវបានពិពណ៌នានៅចុងបញ្ចប់នៃក្របខណ្ឌនេះដែរ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណជាអនេក ដល់ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធទាំងអស់ ជាពិសេសនាយកដ្ឋានធានាគុណភាពអប់រំ ចំពោះការគាំទ្រ និងរៀបចំក្របខណ្ឌដ៏មានសារសំខាន់នេះ ហើយសង្ឃឹមជឿជាក់ថា ក្របខណ្ឌនេះនឹងផ្តល់នូវគន្លងដ៏ច្បាស់លាស់មួយសម្រាប់គ្រប់ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត និងពិនិត្យតាមដានដំណើរការវង្វាយតម្លៃការសិក្សាកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា។

ថ្ងៃ ចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

# សេចក្ដីថ្លែងអំណរគុណ

ក្របខ័ណ្ឌនេះគឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា រវាងនាយកដ្ឋានធានាគុណភាពអប់រំ (EQAD) និងវិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ RTI ដោយមានការពិគ្រោះយោបល់ជាហូរហែរជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រសួង និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា។ ប្រសិនបើពុំមានការចូលរួមរបស់ស្ថាប័នណាមួយ ក្របខ័ណ្ឌនេះប្រហែលជាមិនអាចសម្រេចបានឡើយ។

ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការដឹកនាំប្រកបដោយប្រសិទ្ធភាព ក៏ដូចជាជំរុញនានច្បាស់លាស់ ក្នុងការធ្វើឱ្យកំណែទម្រង់វិស័យអប់រំកើតមានទៅបាន។ ការគាំទ្ររបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ចំពោះក្រុមការងារវង្វាយតម្លៃរបស់នាយកដ្ឋានធានាគុណភាពអប់រំ បានធ្វើឱ្យការងារអភិវឌ្ឍក្របខ័ណ្ឌវង្វាយតម្លៃការសិក្សារបស់សិស្ស ពីកម្រិតមេត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ នេះចេញជារូបរាងទៅបាន។ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះសចំពោះ **ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការដឹកនាំផ្ទាល់ និងការណែនាំប្រកបដោយភាពច្បាស់លាស់។ មតិយោបល់ណែនាំដ៏មានអត្ថន័យ និងស៊ីជម្រៅរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ បានជួយបន្ថែមនូវធាតុចូលសំខាន់ៗសម្រាប់សំណៅចុងក្រោយនៃឯកសារក្របខ័ណ្ឌនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះក្រុមការងារ USAID និង RTI សម្រាប់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ជាពិសេសគឺលោកបណ្ឌិត ចូណាថាន ស្ទើន (Dr. Jonathan Stern) និងលោកស្រីបណ្ឌិត ផេកគី ឌូបេក (Dr. Peggy Dubeck) សម្រាប់ការខិតខំប្រឹងប្រែងក្នុងការប្រមូលព័ត៌មានអំពីការវាយតម្លៃការសិក្សារបស់សិស្សដែលមានស្រាប់ ហើយបានបញ្ចូលព័ត៌មានទាំងនោះទៅក្នុងក្របខ័ណ្ឌនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកបណ្ឌិត **ហេង គ្រេង** ទីប្រឹក្សាថ្នាក់ជាតិរបស់នាយកដ្ឋានធានាគុណភាពអប់រំ សម្រាប់ការប្រឹក្សា និងការគាំទ្រផ្នែកបច្ចេកទេសក្នុងការបញ្ចប់ក្របខ័ណ្ឌនេះបានសព្វគ្រប់។

យើងខ្ញុំក៏សូមអរគុណផងដែរចំពោះ លោកនាយក និងមន្ត្រីជំនាញ មកពីនាយកដ្ឋាន និងស្ថាប័នជំនាញនានារួមមាន DCD, PED, QEMIS, GSED, ECED, TTD, SED, DoP, និង DEA សម្រាប់កិច្ចសហប្រតិបត្តិការ និងការផ្ដល់ធាតុចូលផ្សេងៗ។ ប្រសិនបើគ្មានការចូលរួមពីលោក លោកស្រីទេ ការធ្វើសុខដុមនីយកម្មលើការអនុវត្តការវាយតម្លៃការសិក្សារបស់សិស្ស ប្រាកដជាជួបបញ្ហាប្រឈមជាច្រើន។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់នាយកដ្ឋានធានាគុណភាពអប់រំ ជាពិសេសដល់ការិយាល័យធានាគុណភាពអប់រំ សម្រាប់ការប្ដេជ្ញាចិត្តយ៉ាងមុតមាំចំពោះការងាររដ្ឋបាល និងបច្ចេកទេសទាំងអស់។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ភាគីទាំងអស់ ដែលបានជួយគាំទ្រដល់ក្រុមការងារវាយតម្លៃរបស់យើងខ្ញុំ ដើម្បីបានអនុវត្តការងារគ្រប់ផ្នែកទាំងអស់ក្នុងអំឡុងពេលវាយតម្លៃនេះ។

**រាជធានីភ្នំពេញ ខែមិថុនា ឆ្នាំ2018**

**នាយកដ្ឋានធានាគុណភាពអប់រំ** (EQAD)

# មាតិកា


**បុព្វកថា** ........ i

**សេចក្តីថ្លែងអំណរគុណ** ........ ii

**មាតិកា** ........ iv

**អក្សរកាត់** ........ vi

**តារាង** ........ vii

**រូបភាព** ........ viii

**១. សេចក្តីផ្តើម** ........ 9

១.១. ប្រវត្តិសង្ខេបនៃការវាយតម្លៃផ្នែកអប់រំនៅកម្ពុជា ........ 9

១.២. ហេតុអ្វីត្រូវធ្វើការវាយតម្លៃ? ........ 10

១.៣. ដំណើរការវាយតម្លៃ ........ 10

**២. គោលបំណងនៃការវាយតម្លៃ** ........ 11

២.១. គោលបំណងចុងក្រោយនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ........ 11

២.២. គោលការណ៍គន្លឹះ និងលក្ខណៈវិនិច្ឆ័យក្នុងការដាក់បញ្ចូលការវាយតម្លៃក្នុងក្របខ័ណ្ឌនេះ ... 12

**៣. ការវាយតម្លៃ** ........ 13

៣.១. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់ទី១២ ........ 14

៣.២. ផ្នែកនៃការវាយតម្លៃ និងទំនួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ........ 15

៣.២.១. ការវាយតម្លៃផ្ទៃក្រៅ ........ 17

៣.២.២. ការវាយតម្លៃផ្ទៃក្នុង ........ 23

៣.៣. ដំណើរការធ្វើសុខដុមនីយកម្ម ........ 30

៣.៤. កាលកំណត់ និងការអនុវត្តការវាយតម្លៃ ........ 33

**៤. ការគ្រប់គ្រង និងត្រួតពិនិត្យគុណភាពការវាយតម្លៃ** ........ 38

៤.១. ក្រុមប្រតិបត្តិការវាយតម្លៃ ........ 38

៤.១.១. ការវាយតម្លៃផ្ទៃក្រៅ ........ 39

៤.១.២. ការវាយតម្លៃផ្ទៃក្នុង ........ 42

៤.២. តួនាទីរបស់នាយកដ្ឋានក្នុងការអភិវឌ្ឍសៀវភៅណែនាំ និងគោលការណ៍ណែនាំការវាយតម្លៃ ........ 46

៤.២.១. នាយកដ្ឋានធានាគុណភាពអប់រំ (EQAD) ........ 46

៤.២.២. នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD) ........ 47

៤.២.៣. នាយកដ្ឋានកិច្ចការប្រឡង (DEA) ........ 48

៤.២.៤. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED) ........ 48

៤.២.៥. នាយកដ្ឋានបឋមសិក្សា (PED) ........ 49

៤.២.៦. នាយកដ្ឋានអប់រំកុមារតូច (ECED) ........ 50

៤.២.៧. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ (TTD) ............ 51
៤.២.៨. នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ (EMIS) ............ 51
៤.២.៩. នាយកដ្ឋានអប់រំពិសេស (SED) ............ 52
៤.២.១០. នាយកដ្ឋានគោលនយោបាយ (DPo) ............ 52
៤.២.១១. ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ............ 53
៤.៣. ការប្រើប្រាស់ និងការកែលម្អការវាយតម្លៃ ............ 53
៤.៣.១. ថ្នាក់ជាតិ ............ 53
៤.៣.២. ថ្នាក់ក្រោមជាតិ ............ 53
**ឯកសារយោង** ............ 56

# អក្សរកាត់

| | |
|---|---|
| CBA | ការវាយតម្លៃកម្រិតថ្នាក់រៀន |
| DCD | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| DEA | នាយកដ្ឋានកិច្ចការប្រឡង |
| DoP | នាយកដ្ឋានគោលនយោបាយ |
| DTMT | ក្រុមបណ្តុះបណ្តាល និងពិនិត្យតាមដានថ្នាក់ស្រុក |
| ECED | នាយកដ្ឋានអប់រំកុមារតូច |
| EGRA | តេស្តវាយតម្លៃអំណានថ្នាក់ដំបូង |
| EGMA | តេស្តវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង |
| EMIS | នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ |
| EQAD | នាយកដ្ឋានធានាគុណភាពអប់រំ |
| GPE | គម្រោងភាពជាដៃគូសកលសម្រាប់ការអប់រំ |
| GSED | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| M&E | ការពិនិត្យតាមដាន និងការវាយតម្លៃ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| OECD | អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ |
| PED | នាយកដ្ឋានបឋមសិក្សា |
| PISA-D | កម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ |
| PoE | មន្ទីរអប់រំយុវជន និងកីឡា រាជធានី/ខេត្ត |
| QEMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងគុណភាពអប់រំ |
| SEA-PLM | តេស្តវាយតម្លៃការសិក្សាសម្រាប់សិស្សបឋមសិក្សានៅអាស៊ីអាគ្នេយ៍ |
| SED | នាយកដ្ឋានអប់រំពិសេស |
| TTD | នាយកដ្ឋានបណ្តុះបណ្តាលគ្រូបង្រៀន |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| TGL | ប្រធានក្រុមបច្ចេកទេស |

# តារាង


តារាងទី 1: គោលការណ៍គន្លឹះ និងលក្ខណៈវិនិច្ឆ័យ ....................12
តារាងទី 2: ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់ទី១២ ....................14
តារាងទី 3. ដំណើរការធ្វើសុខដុមនីយកម្ម ....................30
តារាងទី 4: សមាសភាពគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង ....................39
តារាងទី 5: សមាសភាពគណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេសការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង ....................40
តារាងទី 6: សមាសភាពក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង ....................41
តារាងទី 7: សមាសភាពគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង ....................43
តារាងទី 8: សមាសភាពគណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេសការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង ....................44
តារាងទី 9: សមាសភាពក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង ....................45

# រូបភាព


រូបភាពទី 1: ដំណើរការវាយតម្លៃក្នុងទម្រង់ជាវដ្ត ......11
រូបភាពទី 2: ការវាយតម្លៃការសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ ...16
រូបភាពទី 3: ការវាយតម្លៃការសិក្សារបស់សិស្សទៅតាមកម្រិតថ្នាក់ ចំនួនដង និងប្រភេទ ......34
រូបភាពទី 4: ធាតុផ្សំនៃការគ្រប់គ្រង និងត្រួតពិនិត្យលើការវាយតម្លៃ ......38
រូបភាពទី 5: រចនាសម្ព័ន្ធនៃក្រុមប្រតិបត្តិ ......38

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តក្នុងការកែទម្រង់គ្រប់វិស័យទាំងអស់ ដើម្បីសម្រេចឱ្យបានជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង មានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ កត្តាមួយដែលអាចជួយឱ្យសម្រេចបាននូវគោលដៅរយៈពេលវែងនេះ គឺការលើកកម្ពស់ធនធានមនុស្ស។ រាជរដ្ឋាភិបាលព្យាយាមអភិវឌ្ឍធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការកើនឡើងរបស់ប្រទេស។ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) មានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការងារនេះ ហើយកំពុងធ្វើកំណែទម្រង់ទៅតាមផ្នែកផ្សេងៗជាច្រើន។

ក្រសួងអប់រំ យុវជន និងកីឡា មានភារៈកិច្ចផ្តល់ជូនប្រជាជនគ្រប់រូបនូវឱកាសនានាដែលចាំបាច់ ដើម្បីឱ្យពួកគេអាចមានគុណភាពជីវិតខ្ពស់បំផុតសម្រាប់ខ្លួនឯង និងសម្រាប់ប្រទេសកម្ពុជាទាំងមូល។ ការបោះជំហានឆ្ពោះទៅរកការសម្រេចបាននូវគោលដៅនេះ ក្រសួងអប់រំបានប្តេជ្ញាក្នុងការលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន ក៏ដូចជាគុណភាពរបស់ប្រព័ន្ធសាលារៀនឱ្យកាន់តែទូលំទូលាយជាងមុន ដើម្បីជួយឱ្យសិស្សានុសិស្ស ឪពុកម្តាយ សហគមន៍ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាសម្រេចបាននូវស្តង់ដាថ្នាក់ជាតិរួម។ ដើម្បីស្វែងយល់ថាតើ ការអប់រំសម្រេចបានតាមស្តង់ដាថ្នាក់ជាតិដែលបានកំណត់នេះ (ឬសម្រេចបានគោលដៅ) ចាំបាច់ត្រូវមានមធ្យោបាយក្នុងការវាស់វែងវឌ្ឍនភាព និងលទ្ធផលដែលសម្រេចបាន។ ដោយហេតុនេះ ការវាយតម្លៃដែលមានភាពពាក់ព័ន្ធ និងអាចជឿជាក់បានចាំបាច់ត្រូវតែមាន ដើម្បីធានាថា គេកំពុងផ្តល់ការអប់រំប្រកបដោយគុណភាព ធនធានមនុស្សកំពុងត្រូវបានកែលម្អ ហើយប្រទេសកម្ពុជាកំពុងស្ថិតនៅលើផ្លូវដែលត្រឹមត្រូវឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងនិរន្តរភាព។

## ១.១. ប្រវត្តិសង្ខេបនៃការវាយតម្លៃផ្នែកអប់រំនៅកម្ពុជា

ការវាយតម្លៃការអប់រំត្រូវបានប្រើប្រាស់តាមមធ្យោបាយផ្សេងៗ ក្នុងគោលបំណងខុសៗគ្នានៅក្នុងប្រទេសកម្ពុជា។ តាំងពីដើមមក គ្រូបង្រៀនបានប្រើប្រាស់ការវាយតម្លៃជាមធ្យោបាយដើម្បីវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍ គ្រូប្រើប្រាស់ការវាយតម្លៃប្រចាំខែ ឬប្រចាំឆមាស ដើម្បីកំណត់ថាតើ សិស្សរបស់ខ្លួនសម្រេចបានតាមលទ្ធផលសិក្សាដែលបានកំណត់ដែរឬទេ ហើយថាតើសិស្សទាំងនោះគួរឱ្យឡើងទៅថ្នាក់ (ឬកម្រិត) បន្ទាប់ដែរឬទេ។ ជាធម្មតា ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ការប្រឡងថ្នាក់ជាតិ ដើម្បីវាយតម្លៃឱ្យសិស្សឆ្លងភូមិសិក្សា ដូចជាការប្រឡងថ្នាក់ជាតិ ថ្នាក់ទី៦ (ដែលបច្ចុប្បន្នត្រូវបានលុបចោល) ការប្រឡងថ្នាក់ជាតិថ្នាក់ទី៩ និងការប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២ ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើតេស្តសិស្សសម្រាប់ការដំឡើងថ្នាក់ពីបឋមសិក្សា ទៅអនុវិទ្យាល័យ ពីអនុវិទ្យាល័យ ទៅវិទ្យាល័យ និងពីវិទ្យាល័យទៅឧត្តមសិក្សា។ ថ្វីដ្បិតតែមនុស្សទូទៅស្គាល់ដំណើរការ និងការវាយតម្លៃទាំងនេះតាមរយៈប្រព័ន្ធអប់រំក្តី (ឧទាហរណ៍ គ្រូ សិស្ស ភាគីពាក់ព័ន្ធ ។ល។) ប៉ុន្តែមានការវាយតម្លៃផ្សេងទៀត ដែលពុំត្រូវបានយល់ដឹងទូលំទូលាយនៅឡើយទេ។

ចាប់តាំងពីការស្តារឡើងវិញនូវប្រព័ន្ធអប់រំ (ឆ្នាំ១៩៧៩) រហូតមកដល់ឆ្នាំ ២០០០ ការវាយតម្លៃទ្រង់ទ្រាយធំ មិនទាន់មាននៅឡើយទេនៅក្នុងប្រព័ន្ធអប់រំកម្ពុជា។ ជំនួសមកវិញ ប្រព័ន្ធអប់រំសម្បូរទៅដោយការវាយតម្លៃ "ទ្រង់ទ្រាយតូច" (ដែលជាទូទៅត្រូវបានស្គាល់ជា ការវាយតម្លៃកម្រិតសាលា និងថ្នាក់រៀន) ដូចបានរាប់រៀបខាងលើ។ នៅឆ្នាំ ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមឱ្យមានការវាយតម្លៃសិស្សថ្នាក់ជាតិ ដោយមានការគាំទ្រពីធនាគារពិភពលោក។ ជាលទ្ធផល ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ និងទី៨ ត្រូវបានអនុវត្តជាផ្លូវការចាប់តាំងពីឆ្នាំ ២០០៧ ចំណែកការវាយតម្លៃថ្នាក់ជាតិថ្នាក់ទី១១ ត្រូវបានអនុវត្តសាកល្បងជាផ្លូវការនៅក្នុងឆ្នាំ ២០១៨។ ហើយកាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាបានចូលរួមនៅក្នុងការវាយតម្លៃទ្រង់ទ្រាយធំកម្រិតអន្តរជាតិ និងថ្នាក់តំបន់ថែមទៀត (PISA-D នៅឆ្នាំ ២០១៦ និង SEA-PLM នៅឆ្នាំ ២០១៥)។

ជាលទ្ធផល ប្រព័ន្ធអប់រំកម្ពុជាអនុវត្តនូវការវាយតម្លៃចម្រុះជាច្រើនសម្រាប់ពិនិត្យមើលពីការសិក្សារបស់សិស្ស (រាប់បញ្ចូលទាំងការវាយតម្លៃដែលបានលើកឡើងពីខាងដើមនៅក្នុងសេចក្តីផ្តើមនេះផង)។ តែជាអកុសល គោលបំណង និងភាពពាក់ព័ន្ធនៃការវាយតម្លៃទាំងអស់នេះ ជារឿយៗ មិនត្រូវបានស្វែងយល់ច្បាស់លាស់ដោយអ្នកអនុវត្ត និងអ្នកអប់រំឡើយ។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចអភិវឌ្ឍក្របខ័ណ្ឌមួយដែលមានប្រសិទ្ធភាព និងអាចយកទៅអនុវត្តបាន សម្រាប់ប្រទេសទាំងមូល ដើម្បីសង្ខេប និងធ្វើសុខដុមនីយកម្មលើដំណើរការវាយតម្លៃដែលខុសៗគ្នាទាំងអស់នេះ។

## ១.២. ហេតុអ្វីត្រូវធ្វើការវាយតម្លៃ?

គោលដៅចុងក្រោយបំផុតនៃការវាយតម្លៃនៅក្នុងប្រព័ន្ធអប់រំ គឺដើម្បីផ្តល់ជាមធ្យោបាយមួយសម្រាប់ការស្វែងយល់ និងកែលម្អលទ្ធផលសិក្សារបស់សិស្ស។ ជាទូទៅ ការវាយតម្លៃ អាចវិនិច្ឆ័យលើគុណភាព ប្រសិទ្ធភាព គុណតម្លៃ និងតម្លៃរបស់ប្រព័ន្ធ កម្មវិធី ផលិតផល និងការអនុវត្តផ្សេងៗបាន។ តាមរយៈការវាយតម្លៃ យើងក៏អាចរកឃើញពីលទ្ធផលសិក្សា និងឥរិយាបថផ្សេងៗថែមទៀតផង (ឧទាហរណ៍ ការយល់ដឹងលើខ្លឹមសារ ជំនាញ អក្ខរភាព លេខនព្វន្ត ជំនាញត្រិះរិះ។ល។) ។ ដូច្នេះ ការវាយតម្លៃមានសារៈសំខាន់ចំពោះភាពជោគជ័យរបស់ប្រព័ន្ធអប់រំ ពីព្រោះការវាយតម្លៃអាចជួយដល់អ្នកអប់រំ និងភាគីពាក់ព័ន្ធធ្វើការសម្រេចចិត្តលើប្រព័ន្ធ កម្មវិធី ផលិតផល ឬការអនុវត្តទាំងនោះបាន។ តែទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃចាំបាច់ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

## ១.៣. ដំណើរការវាយតម្លៃ

គោលវិធីដែលសមស្របសម្រាប់ការវាយតម្លៃ តម្រូវឱ្យមានការប្រព្រឹត្តទៅលើសពីមួយជំហាន។ គោលវិធីនេះអាចត្រូវបានអនុវត្តតាមវដ្តជាប្រព័ន្ធ ដូចជា វដ្តប្រាំជំហាន ដែលមានបង្ហាញក្នុងរូបភាពទី១ខាងក្រោម។

*រូបភាពទី 1: ដំណើរការវាយតម្លៃក្នុងទម្រង់ជាវដ្ត*




ជំហានទី១ នៅក្នុងវដ្តនៃការវាយតម្លៃនេះ គឺតម្រូវឱ្យអ្នកវាយតម្លៃធ្វើការកំណត់រកលទ្ធផលសិក្សាដែលពាក់ព័ន្ធ។ បន្ថែមលើនេះទៀត ចាំបាច់ត្រូវស្វែងយល់ពីឱកាសការសិក្សាដែលបានជួយឱ្យអ្នកសិក្សាក្រេបយកចំណេះដឹង និងជំនាញផ្សេងៗ ដើម្បីសម្រេចបាននូវលទ្ធផលសិក្សាទាំងអស់នោះ។ បន្ទាប់មក ដំណើរការវាយតម្លៃ ត្រូវបានធ្វើឡើង (ចំពោះសិស្សដែលត្រូវបានជ្រើសរើសដែលត្រូវបានហៅថា សំណាក ឬក្រុមគោលដៅទាំងអស់)។ បន្ទាប់មកទៀត អ្នកវាយតម្លៃ (ឬអ្នកជំនាញបច្ចេកទេស) ចាំបាច់ត្រូវវិភាគលើទិន្នន័យ ទាញសេចក្តីសន្និដ្ឋាន និងពិភាក្សាលើលទ្ធផល និងភាពពាក់ព័ន្ធ។ ជាចុងក្រោយ ហើយប្រហែលជាចំណុចសំខាន់បំផុតនោះគឺ ត្រូវធ្វើការផ្លាស់ប្តូរ/កែលម្អ/កែសម្រួល។ល។ ដោយផ្អែកលើលទ្ធផលទាំងអស់នោះ។ ប្រសិនបើគ្មានជំហានចុងក្រោយនេះទេ នោះការវាយតម្លៃនឹងមានលទ្ធភាពតិចតួចប៉ុណ្ណោះក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ និងកែលម្អលទ្ធផលរបស់សិស្ស ដើម្បីសម្រេចបានតាមលទ្ធផលសិក្សា ក៏ដូចជាពង្រឹងប្រព័ន្ធអប់រំទាំងមូល។

## ២. គោលបំណងនៃការវាយតម្លៃ

### ២.១. គោលបំណងចុងក្រោយនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

គោលបំណងសំខាន់នៃក្របខ័ណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនេះ គឺដើម្បីបង្ហាញពីទិដ្ឋភាពទូទៅរបស់ការវាយតម្លៃទាំងអស់ ដែលបានរៀបចំឡើងសម្រាប់ការវាស់វែងទៅលើលទ្ធផលសិក្សារបស់សិស្សនៅក្នុងប្រព័ន្ធអប់រំពីកម្រិតថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២ នៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត ដូចគ្នាទៅនឹងក្របខ័ណ្ឌវាយតម្លៃផ្សេងទៀតដែរ គោលដៅសំខាន់គឺផ្តោតលើការធានាថា រាល់ការវាយតម្លៃទាំងអស់សមស្របទៅតាមគោលបំណង ការបំពេញបន្ថែម (ប៉ុន្តែលុបបំបាត់រាល់ភាព

ច្រំដែល) និងមានប្រសិទ្ធភាព (ដើម្បីបង្កើនពេលវេលា ដែលអាចលៃទុកសម្រាប់ការបង្រៀន និងការរៀន)។ ប៉ុន្តែ ថ្វីដ្បិតតែការវាយតម្លៃនីមួយៗមានគោលដៅ និងគោលបំណងជាក់លាក់របស់ខ្លួនក៏ដោយ ក៏ការវាយតម្លៃនីមួយៗមិនអាចគ្របដណ្តប់លើគ្រប់ទិដ្ឋភាព ឬបម្រើដល់គ្រប់មុខងារបានទាំងអស់នោះទេ ដូច្នេះការវាយតម្លៃត្រូវបម្រើដល់គោលបំណងដូចខាងក្រោមដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំ៖

| | |
|---|---|
| ដើម្បីផ្តល់ជាភស្តុតាងផ្សេងៗសម្រាប់ការសិក្សា | ការវាយតម្លៃត្រូវតែអាចប្រមូលព័ត៌មានដែលពាក់ព័ន្ធទាំងអស់ដែលទាក់ទងនឹងប្រព័ន្ធ ព្រមទាំងបុគ្គល ស្ថាប័ន ឬអ្នកពាក់ព័ន្ធនានានៅក្នុងប្រព័ន្ធអប់រំ។ |
| ដើម្បីជាព័ត៌មានសម្រាប់គោលនយោបាយ/ផែនការសកម្មភាព | លទ្ធផលនៃការវាយតម្លៃ ត្រូវតែអាចយកមកប្រើដើម្បីជាព័ត៌មានដែលមានប្រយោជន៍ចំពោះគ្រូបង្រៀន ថ្នាក់ដឹកនាំសាលារៀន អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធទាំងអស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងឥទ្ធិពលរបស់ប្រព័ន្ធនោះ ក្នុងការអប់រំ។ |
| ដើម្បីកែលម្អការបង្រៀន និងរៀន | លទ្ធផលនៃការវាយតម្លៃ និងការសន្និដ្ឋាន ត្រូវតែយកមកប្រើ ដើម្បីអភិវឌ្ឍជាអនុសាសន៍ ដែលអាចគាំទ្រ និងកែលម្អប្រព័ន្ធអប់រំ ជាពិសេសទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ |

ក្របខ័ណ្ឌវាយតម្លៃនេះបង្ហាញពីការជួយបំពេញឱ្យគ្នាទៅវិញទៅមកនៃការវាយតម្លៃការសិក្សារបស់សិស្សផ្សេងៗគ្នា ដើម្បីផ្តល់អត្ថប្រយោជន៍ដល់សាលារៀន និងប្រព័ន្ធអប់រំទាំងមូល និងដើម្បីនាំផ្លូវឱ្យមាននវានុវត្តន៍ និងការកែទម្រង់ ជាពិសេស គឺតួនាទីរបស់តួអង្គសំខាន់ៗក្នុងការអនុវត្ត និងពិនិត្យតាមដាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ២.២. គោលការណ៍គន្លឹះ និងលក្ខណៈវិនិច្ឆ័យក្នុងការដាក់បញ្ចូលការវាយតម្លៃក្នុងក្របខ័ណ្ឌនេះ

តារាងខាងក្រោមនេះបង្ហាញពីទិដ្ឋភាពទូទៅនៃគោលការណ៍គន្លឹះរបស់ក្របខ័ណ្ឌវាយតម្លៃ និងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទាំងអស់ដែលមានបញ្ចូលនៅក្នុងនោះ។

*តារាងទី 1: គោលការណ៍គន្លឹះ និងលក្ខណៈវិនិច្ឆ័យ*

| ក្របខណ្ឌវង្វាយតម្លៃនេះធានាថា៖ |
|---|
| គោលបំណងរបស់ការវាយតម្លៃត្រូវបានកំណត់ច្បាស់លាស់ |
| ការវាយតម្លៃមានសុពលភាពតាមគោលបំណងដែលបានកំណត់ |
| ការវាយតម្លៃផ្តល់នូវព័ត៌មានជាក់ច្បាស់ដែលត្រូវការ (ជៀសវាងព័ត៌មានលើសមិនត្រូវការ) |
| មានការកំណត់ច្បាស់លាស់នូវលទ្ធផលសង្ឃឹមទុកលើការប្រើប្រាស់ទិន្នន័យដែលបានមកពីការវាយតម្លៃ |
| ការវាយតម្លៃទាំងអស់(ទាំងដោយឡែក និងទាំងរួមគ្នា) ត្រូវបានរៀបចំឡើង ដោយមិនត្រូវការចំណាយពេលវេលាក្នុងការពន្យល់ណែនាំយូរលើសលុបឡើយ |

| |
|---|
| វិសាលភាពរបស់ការវាយតម្លៃត្រូវសមស្របទៅនឹងទំហំហិរញ្ញប្បទានទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត |
| មានសេចក្តីណែនាំសម្រាប់ការអភិវឌ្ឍការវាយតម្លៃ និងការអនុវត្តការវាយតម្លៃ ព្រមទាំងការប្រើប្រាស់ទិន្នន័យដែលទទួលបានពីការវាយតម្លៃ* |

** គោលការណ៍នេះ កម្រនឹងអាចបំពេញបាន ហើយតម្រូវឱ្យមានការពិចារណាបន្ថែមទៀត។*

ជាងនេះទៅទៀត ក្របខ័ណ្ឌវាយតម្លៃការសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ នេះ ត្រូវបានរៀបចំឡើងដោយដាក់បញ្ចូលរាល់ការវាយតម្លៃទាំងឡាយណា ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

១. រាល់ការវាយតម្លៃទាំងអស់ ត្រូវផ្តោតលើការវាស់វែងលើលទ្ធផលសិក្សារបស់សិស្ស និង/ឬ តម្រូវការរៀនសូត្ររបស់សិស្ស។
២. ក្របខ័ណ្ឌនេះគ្របដណ្តប់រាល់ការវាយតម្លៃ ដែលបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ (ឧទាហរណ៍ នាយកដ្ឋានថ្នាក់ជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរថ្នាក់ខេត្ត និងការិយាល័យថ្នាក់ស្រុក សាលារៀន និងគ្រូបង្រៀន) និងគ្រប់គោលបំណងទាំងអស់ (ឧទាហរណ៍ វាយតម្លៃតាមដំណាក់នីមួយៗ ពេលបញ្ចប់ការបង្រៀន ការវិនិច្ឆ័យ និងការត្រួតពិនិត្យ ។ល។)
៣. ក្របខ័ណ្ឌនេះគ្របដណ្តប់លើការវាយតម្លៃផ្នែកអប់រំទាំងអស់ លើកលែងនៅកម្រិតឧត្តមសិក្សា។ ដូចនេះ រាល់ការវាយតម្លៃទាំងអស់ចាប់តាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ទី១២ ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌនេះ។
៤. បន្ថែមលើនេះ មានតែការវាយតម្លៃណាដែលត្រូវបានអនុវត្តជាទូទៅក្នុងប្រព័ន្ធអប់រំប៉ុណ្ណោះ (ឬមានបំណងអនុវត្តដូច្នេះ) ដែលត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌនេះ។

ដូច្នេះ ការវាស់វែងពីលទ្ធផលផ្សេងទៀតរបស់គ្រូបង្រៀន បរិយាកាសសាលារៀន ការចូលរួមពីឪពុកម្តាយ/សហគមន៍។ល។ បើទោះជាមានសារៈសំខាន់ដល់ភាពជោគជ័យផ្នែកអប់រំក៏ដោយ ក៏មិនត្រូវបានរាប់បញ្ចូលក្នុងក្របខ័ណ្ឌនេះដែរ។ ការវាយតម្លៃ ដែលកំពុងត្រូវបានប្រើប្រាស់នាពេលបច្ចុប្បន្ន នៅក្នុងគម្រោងខ្នាតតូច ឬកម្មវិធីសាកល្បងនានា (ដោយពុំមានសញ្ញាបង្ហាញច្បាស់លាស់ថា នឹងពង្រីកវិសាលភាព) ឬការវាយតម្លៃដែលកំពុងត្រូវបានប្រើប្រាស់ដោយដៃគូអភិវឌ្ឍន៍ ឬស្ថាប័នដទៃទៀតក្រៅពីក្រសួងអប់រំ យុវជន និងកីឡា ក៏មិនត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌនេះផងដែរ។

## ៣. ការវាយតម្លៃ

កន្លងមក មានការវាយតម្លៃជាច្រើនត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចធ្វើសុខដុមនីយកម្មការវាយតម្លៃទាំងនេះដោយផ្អែកលើ

គោលការណ៍ និងគោលបំណងដែលការវាយតម្លៃនោះបម្រើឱ្យ។ ការវាយតម្លៃទាំងនោះត្រូវបានសង្ខេបជូនក្នុងតារាង២ខាងក្រោម។

### ៣.១. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់ទី១២

បន្ទាប់ពីធ្វើសុខដុមនីយកម្មលើការវាយតម្លៃទាំងអស់ ក៏ដូចជាការដាក់បញ្ចូលបន្ថែមនូវការវាយតម្លៃផ្សេងទៀត ជាចុងក្រោយ មានការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សចំនួនដប់ពីរ ដែលត្រូវបានសម្រេចដាក់បញ្ចូលនៅក្នុងក្របខ័ណ្ឌវាយតម្លៃនេះ។ ដើម្បីឱ្យមានភាពងាយស្រួល និងច្បាស់លាស់ ការវាយតម្លៃទាំង១២ ត្រូវបានផ្តុំជាពីរផ្នែក ដែលគោរពតាមឯកសារណែនាំស្តីពីការងារអធិការកិច្ច និងការធានាគុណភាពរបស់ នាយកដ្ឋានធានាគុណភាពអប់រំ។ ការវាយតម្លៃទាំងនោះមាន ការវាយតម្លៃផ្ទៃក្រៅ និងការវាយតម្លៃផ្ទៃក្នុង។

*តារាងទី 2: ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់ទី១២*

| ផ្ទៃក្រៅ | | ផ្ទៃក្នុង | |
|---|---|---|---|
| **ការវាយតម្លៃកម្រិតអន្តរជាតិ និងថ្នាក់តំបន់** | **ការវិនិច្ឆ័យទៅលើប្រព័ន្ធថ្នាក់ជាតិ** | **ការវាយតម្លៃបញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា កម្រិតសាលារៀន និងថ្នាក់រៀន** | **ការវាយតម្លៃតាមដំណាក់សម្រាប់អភិវឌ្ឍន៍កម្រិតសាលារៀន និងថ្នាក់រៀន** |
| តេស្តវង្វាយតម្លៃកម្រិតអន្តរជាតិ PISA | តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ | ប្រឡងថ្នាក់ជាតិថ្នាក់ទី៩ | ការវាយតម្លៃកម្រិតមត្តេយ្យ/ការត្រៀមលក្ខណៈចូលសាលា |
| តេស្តវង្វាយតម្លៃលទ្ធផលសិក្សាសម្រាប់សិស្សបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) | ប្រឡងថ្នាក់ជាតិថ្នាក់ទី១២ | ប្រឡងឡើងថ្នាក់ | ប្រឡងប្រចាំខែ |
| | តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង (EGRA) | ប្រឡងឆមាស/អំណានស្ទាត់ | ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀន |
| | តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង (EGMA) | | |

### ៣.២. ផ្នែកនៃការវាយតម្លៃ និងទំនួលខុសត្រូវរបស់ស្ថាប័ននីមួយៗ

តាមរយៈដំណើរការសុខដុមនីយកម្មនេះ កម្មវិធីសិក្សា ការបង្រៀន និងរៀន និងការវាយតម្លៃសិស្ស ត្រូវមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតចាប់តាំងពីកម្រិតថ្នាក់រៀន រហូតដល់កម្រិតសាលារៀន ថ្នាក់ស្រុក ថ្នាក់ខេត្ត និងចុងក្រោយគឺថ្នាក់ជាតិ ហើយចរន្តនេះត្រូវវត់ត្រាសមកវិញ។ ដំណើរការនេះក៏ធានាឱ្យមានលំហូរឥតដាច់ នៃទម្លាប់វាយតម្លៃការសិក្សារបស់សិស្ស និងប្រព័ន្ធពិនិត្យតាមដាន ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សស្របតាមផែនការយុទ្ធសាស្ត្រអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ផ្នែកអប់រំ (Education SDG4)។ រូបភាពខាងក្រោមនេះពណ៌នាអំពីអន្តរកម្មរវាងការវាយតម្លៃគ្រប់ប្រភេទទាំងអស់ និងអង្គភាពអនុវត្តនៅក្នុងក្របខ័ណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់មធ្យមសិក្សា។ ដូចដែលបានបង្ហាញជូន បច្ចុប្បន្នការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមានចំនួនបួនប្រភេទដែលកំពុងតែអនុវត្តក្នុងគោលបំណងផ្សេងៗ។ ប្រសិនបើគ្មានការខ័ណ្ឌចែកឱ្យបានច្បាស់លាស់ និងការធ្វើសុខដុមនីយកម្មនៅក្នុងក្របខ័ណ្ឌនេះទេ នោះការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅតែផ្តោតលើករណីនីមួយៗ មិនត្រូវតាមគោលបំណង ហើយអាចស្ទួនគ្នាផងដែរ។ ក្របខ័ណ្ឌនេះបង្ហាញថាតើការវាយតម្លៃនីមួយៗនៅត្រង់ណា ហើយប្រើកន្លែងណា ដើម្បីឱ្យអ្នកអនុវត្ត និងអ្នកត្រួតពិនិត្យអាចទទួលបានការណែនាំកាន់តែប្រសើរជាងមុនសម្រាប់ការងារជាប្រចាំរបស់ខ្លួន។

១. សំណុំវាយតម្លៃទីមួយនៃការវាយតម្លៃគឺការវាយតម្លៃកម្រិតថ្នាក់រៀន ដែលត្រូវបានអនុវត្តជាប្រចាំ និងដឹកនាំដោយគ្រូ។ ការវាយតម្លៃទាំងនេះផ្តោតសំខាន់លើការអភិវឌ្ឍ និងការសិក្សារបស់សិស្ស។ ការប្រើប្រាស់ការវាយតម្លៃទាំងនេះ អាចប្រកបដោយអត្ថន័យតាមរយៈការគាំទ្របច្ចេកទេសពីថ្នាក់កម្រង និង/ឬថ្នាក់ស្រុក។ នាយកសាលាគួរជំរុញពង្រឹងការវាយតម្លៃនេះ តាមរយៈការពិនិត្យតាមដានជាប្រចាំ ឬក៏ភ្ជាប់ការវាយតម្លៃនេះទៅនឹងការវាយតម្លៃដោយសាលាខ្លួនឯង ដែលបច្ចុប្បន្នការធ្វើដូច្នេះត្រូវបានតម្រូវឱ្យមាននៅក្នុងការពិនិត្យតាមដានរបស់ក្រុមបណ្តុះបណ្តាល និងពិនិត្យតាមដានថ្នាក់ស្រុក (DTMT)។

២. សំណុំវាយតម្លៃទីពីរគឺការវាយតម្លៃនៅកម្រិតសាលា ជាមួយនឹងគោលបំណងវិនិច្ឆ័យ និងដើម្បីឱ្យសិស្សឆ្លងកម្រិតថ្នាក់ និងភូមិសិក្សា។ ប៉ុន្តែរបៀបអនុវត្តការវាយតម្លៃនេះមិនបានផ្សារភ្ជាប់ទំនាក់ទំនងច្បាស់លាស់ជាមួយនឹងការងាររបស់ថ្នាក់កម្រង ឬការងាររបស់ការិយាល័យអប់រំស្រុក (DoE) ឡើយ ។ ភាពដូចគ្នា ឬឯកសណ្ឋានភាព និងគុណភាពរបស់ការវាយតម្លៃទាំងនេះគឺមានសារៈសំខាន់ខ្លាំងណាស់ បើតាមទំនោរ និងលក្ខណៈនៃការវាយតម្លៃរបស់សំណុំនេះ។ ដូច្នេះក្រៅពីនាយកសាលា ថ្នាក់កម្រង និងថ្នាក់ស្រុកគួរតែដើរតួនាទីពិនិត្យតាមដានឱ្យបានល្អនៅក្នុងការងារនេះ។

*រូបភាពទី 2: ការវាយតម្លៃការសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ*



៣. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងសំណុំទីបី គឺជាការវាយតម្លៃបញ្ចប់ភូមិសិក្សា ដែលអនុវត្តនៅកម្រិតថ្នាក់ទី៩ និងទី១២តាមរយៈការប្រឡងថ្នាក់ជាតិដើម្បីដំឡើងថ្នាក់សិស្សទៅកាន់ថ្នាក់ទី១០ និងទៅសកលវិទ្យាល័យ។ បច្ចុប្បន្ន ការប្រឡងថ្នាក់ទី១២ ត្រូវបានរៀបចំទូទាំងប្រទេស ហើយដឹកនាំដោយនាយកដ្ឋានកិច្ចការប្រឡង (DEA) ចំណែកឯការប្រឡងថ្នាក់ទី៩ ការវាយតម្លៃផ្ទៃក្នុង ដោយឱ្យសាលានីមួយៗជាអ្នកអនុវត្តការវាយតម្លៃនេះ។ ជាហេតុដែលនាំឱ្យមានការបារម្ភណ៍ខ្លាំង ចំពោះការប្រៀបធៀបពិន្ទុពីសាលាមួយទៅសាលាមួយទៀតសម្រាប់ការប្រឡងថ្នាក់ទី៩នេះ។ ដូច្នេះ ភាពដូចគ្នា ឬឯកសណ្ឋានភាព និងគុណភាពរបស់ការវាយតម្លៃទាំងនេះ គឺជាចំណុចសំខាន់ខ្លាំងណាស់។

៤. ការវាយតម្លៃក្នុងសំណុំចុងក្រោយ គឺជាការវាយតម្លៃទ្រង់ទ្រាយធំ និងសមស្របសម្រាប់ការវិនិច្ឆ័យលើប្រព័ន្ធអប់រំទាំងមូល។ ការវាយតម្លៃនេះដឹកនាំដោយ នាយកដ្ឋានធានាគុណភាពអប់រំ ប៉ុន្តែឥទ្ធិពលរបស់ការវាយតម្លៃនេះអាចមានទៅបាន លុះត្រាតែអន្តរគមន៍ផ្សេងៗដែលផ្អែកលើភស្តុតាង ពិតជាត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លទ្ធផលបានមកពីការវាយតម្លៃនេះគួរយកទៅប្រើសម្រាប់ការបង្កើតគោលនយោបាយជាប្រព័ន្ធ ការកសាងផែនការ និងកិច្ចអន្តរាគមន៍ផ្សេងៗ។

ជារួម ដូចដែលបានឃើញនៅក្នុងផ្ទៃកស្នូលរបស់រូបភាពខាងលើ និងដោយអាស្រ័យលើការអនុវត្ត *មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត (PoE)* ត្រូវបានមើលឃើញថាជាតួអង្គយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់គ្នារវាងការវាយតម្លៃគ្រប់ប្រភេទទាំងអស់ និងក្នុងការធានាថា ការសិក្សារបស់សិស្សត្រូវបានវាយតម្លៃត្រឹមត្រូវ (ស្របតាមគោលបំណង) ហើយលទ្ធផលនៃការវាយតម្លៃមានសារៈប្រយោជន៍ក្នុងការផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅដែលមានស្រាប់។

### ៣.២.១. ការវាយតម្លៃផ្ទៃក្រៅ

ការវាយតម្លៃទាំងនេះធ្វើឡើងដោយអ្នកខាងក្រៅហើយនាំយកទៅកាន់សាលារៀន។ ដូច្នេះ ការវាយតម្លៃទាំងនេះត្រូវបានអនុវត្តដោយបុគ្គលិកក្រសួងនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ឬថ្នាក់ស្រុក។

ក. <u>ការវាយតម្លៃកម្រិតអន្តរជាតិ និងថ្នាក់តំបន់</u>៖ ការវាយតម្លៃទាំងនេះត្រូវបានរាប់បញ្ចូលរាល់ការវាយតម្លៃទាំងអស់ ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងវាស់វែងពីលទ្ធផលដោយធៀបនឹងស្តង់ដាអន្តរជាតិ។ សម្រាប់ការវាយតម្លៃទាំងនេះ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលចូលរួមនៅក្នុងការវាយតម្លៃ ដែលគោរពតាមគោលការណ៍ណែនាំ ការរៀបចំ និងការអភិវឌ្ឍសំណួរតេស្ត ជាលក្ខណៈអន្តរជាតិ ឬថ្នាក់តំបន់ ជាមួយនឹងស្តង់ដាច្បាស់លាស់ ដែលអនុញ្ញាតឱ្យមានការប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយទៀតបាន។

ខ. <u>ការវិនិច្ឆ័យលើប្រព័ន្ធថ្នាក់ជាតិ</u>៖ ការវាយតម្លៃទាំងនេះត្រូវបានអនុវត្តទូទាំងប្រទេស ប៉ុន្តែការងារទទួលខុសត្រូវ និងការត្រួតពិនិត្យសម្រាប់ការវាយតម្លៃទាំងនេះ គឺចាប់តាំងពីថ្នាក់កណ្តាល រហូតដល់កម្រិតសាលារៀន។ ការវាយតម្លៃទាំងនេះត្រូវបានបង្កើត

ឡើងក្នុងគោលបំណងវាស់វែងពីដំណើរការរបស់ប្រព័ន្ធទាំងមូល ដោយមានគោលដៅកំណត់រកចំណុចខ្លាំង និងចំណុចត្រូវកែលម្អសម្រាប់ប្រព័ន្ធ។

**PISA សម្រាប់ការអភិវឌ្ឍ (PISA-D)**

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានធានាគុណភាពអប់រំ (EQAD) (ក្រោមការគាំទ្រពី OECD) ទទួលខុសត្រូវក្នុងការកសាងតេស្ត និងការគ្រប់គ្រង់ការអនុវត្ត ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ ក៏ដូចជាការសរសេររបាយការណ៍ និងផ្សព្វផ្សាយ។ រាល់ទិដ្ឋភាពទាំងអស់នៃការវាយតម្លៃនេះត្រូវបានអនុវត្តនៅថ្នាក់កណ្តាលនៃក្រសួង។

**ទិដ្ឋភាពទូទៅ៖** PISA-D ចូលមកកម្ពុជាជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់ OECD ដើម្បីជំរុញ និងសម្របសម្រួលឱ្យមានការចូលរួមជាមួយ PISA ពីសំណាក់ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំង៩ ដែលបានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមនេះ ដោយប្រើប្រាស់ឱកាសនេះដើម្បីបានរៀនសូត្រពីអ្នកជំនាញអន្តរជាតិ អំពីរបៀបអនុវត្តការវាយតម្លៃទ្រង់ទ្រាយធំឱ្យបានល្អបំផុត និងពីរបៀបប្រើប្រាស់ទិន្នន័យទាំងនេះជាភស្តុតាងក្នុងការសម្រេចចិត្ត។ ការវាយតម្លៃនេះមិនមែនផ្អែកលើកម្មវិធីសិក្សារបស់ប្រទេសនីមួយៗដែលចូលរួមនោះទេ ប៉ុន្តែ ផ្អែកលើក្របខ័ណ្ឌសមត្ថភាពសកល ហើយត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាការវិនិច្ឆ័យលើប្រព័ន្ធតំណាងថ្នាក់ជាតិសម្រាប់សិស្សអាយុ ១៥ ឆ្នាំទៅលើមុខវិជ្ជាគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ។ ការវាយតម្លៃនេះក៏មានគោលដៅយកទៅប្រើសម្រាប់ការប្រៀបធៀបជាលក្ខណៈអន្តរជាតិ (ពីព្រោះពិន្ទុពីគ្រប់បណ្តាប្រទេសទាំងអស់នឹងត្រូវបានថ្លឹង និងបញ្ចូលទៅក្នុងតារាងចំណាត់ថ្នាក់)។ ការអនុវត្តទៅតាមវដ្តនៃការវាយតម្លៃនេះនៅថ្ងៃក្រោយនឹងអនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា អាចពិនិត្យមើលពីនិន្នាការនានាក្នុងរយៈកាលណាមួយផងដែរ។ ទិន្នន័យ PISA-D ត្រូវបានប្រមូលនៅចុងឆ្នាំ ២០១៧ ជាមួយនឹងសំណាកតំណាងថ្នាក់ជាតិនៃសិស្សអាយុ ១៥ឆ្នាំ។

> ***កំណត់សម្គាល់៖***
> *PISA-D ជាកម្មវិធីវាយតម្លៃតែម្តងគត់ដែលផ្តួចផ្តើមដោយអង្គការ OECD។ ប្រទេសកម្ពុជាបានចូលរួមនៅក្នុងកម្មវិធីនេះចាប់ពីឆ្នាំ២០១៦ និងបានបញ្ចប់ដោយជោគជ័យនៅក្នុងឆ្នាំ២០១៨ ជាមួយនឹងលទ្ធផលគួរជាទីមោទនៈ និងបទពិសោធន៍ល្អៗជាច្រើន។ ប្រទេសកម្ពុជាបានសម្រេចចូលរួមជាមួយកម្មវិធី PISA ជាផ្លូវការហើយ ដែលត្រូវចាប់ផ្តើមធ្វើវដ្តដំបូងរបស់ខ្លួននៅក្នុងឆ្នាំ២០២១ ជាមួយនឹងវដ្ត៣ឆ្នាំ។ ដូចនេះ កម្មវិធី PISA នឹងជំនួសឱ្យកម្មវិធី PISA-D នៅក្នុងបរិបទកម្ពុជាចាប់ពីពេលនេះទៅ។*

**ផលជះ/ការប្រើប្រាស់៖** ចំណុចចម្បង និងសំខាន់បំផុតនោះ គឺ PISA-D ជាលំហាត់កសាងសមត្ថភាពសម្រាប់នាយកដ្ឋានធានាគុណភាពអប់រំ។ ទោះជាយ៉ាងណា ទិន្នន័យនេះក៏មានតម្លៃដើម្បីស្វែងយល់ថាតើយុវជនកម្ពុជាអាយុ ១៥ឆ្នាំ ធ្វើបានលទ្ធផលដូចម្តេចធៀបនឹងស្តង់ដាអន្តរជាតិ ក៏ដូចជាស្វែងយល់ថាតើប្រទេសកម្ពុជាទទួលបានលទ្ធផលបែបណាធៀបនឹងប្រទេសផ្សេងទៀតដែលចូលរួម

ក្នុងការវាយតម្លៃនេះ។ នាយកដ្ឋានធានាគុណភាពអប់រំ ទទួលខុសត្រូវក្នុងការផ្សព្វផ្សាយលទ្ធផល ប៉ុន្តែ នាយកដ្ឋានផ្សេងទៀតគួរគិតពិចារណាឱ្យបានស៊ីជម្រៅ ថាតើលទ្ធផលនេះរៀបរាប់ពីអ្វីខ្លះអំពីសមត្ថភាពរបស់សិស្ស ហើយលទ្ធផលទាំងនោះអាចយកទៅប្រើបានយ៉ាងដូចម្តេច ដើម្បីដោះស្រាយចំណុចខ្វះខាតនៅក្នុងប្រព័ន្ធអប់រំ។

### តេស្តវាយតម្លៃការសិក្សាសម្រាប់សិស្សបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM)

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានធានាគុណភាពអប់រំ (EQAD) ទទួលខុសត្រូវក្នុងការកសាងតេស្ត និងការគ្រប់គ្រងការអនុវត្ត ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ ក៏ដូចជាការសរសេររបាយការណ៍ និងផ្សព្វផ្សាយ។ រាល់ទិដ្ឋភាពទាំងអស់នៃការវាយតម្លៃនេះត្រូវបានអនុវត្តនៅថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា។

**ទិដ្ឋភាពទូទៅ៖** SEA-PLM គឺជាតេស្តវាយតម្លៃលទ្ធសិក្សារបស់សិស្សផ្អែកលើកម្មវិធីសិក្សារួមមួយ ដែលត្រូវបានបង្កើតឡើងពិសេសសម្រាប់តែបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការវាយតម្លៃនៅកម្រិតថ្នាក់ទី៥នេះ ផ្តោតលើការអភិវឌ្ឍ ផ្នែកអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល។ ការវាយតម្លៃនេះក៏មានកម្រងសំណួរសាវតារ ក្នុងគោលបំណងដើម្បីប្រមូលយកទិន្នន័យអំពីសិស្ស ឪពុកម្តាយ គ្រូបង្រៀន និងសាលារៀន។ ការអនុវត្តដំបូងនៅក្នុងប្រទេសកម្ពុជាគឺគ្រោងធ្វើឡើងនៅឆ្នាំ ២០១៩។

**ផលជះ/ការប្រើប្រាស់៖** SEA-PLM ធ្វើការវិនិច្ឆ័យលើសំណាកថ្នាក់ជាតិនៃសិស្សថ្នាក់ទី៥ ស្របតាមស្តង់ដាថ្នាក់តំបន់ទៅលើមុខវិជ្ជាចំនួនបួន។ លទ្ធផលពីការវាយតម្លៃនេះអាចយកទៅប្រើប្រាស់ដើម្បីជាព័ត៌មានសម្រាប់ការកែលម្អប្រព័ន្ធអប់រំ (តាមរយៈមធ្យោបាយនានា ដូចជាការបណ្តុះបណ្តាលគ្រូបង្រៀន និងការគ្រប់គ្រងសាលារៀន)។ ព័ត៌មាននេះក៏នឹងត្រូវប្រើប្រាស់ដើម្បីប្រៀបធៀបក្នុងថ្នាក់តំបន់ (ដើម្បីកំណត់រកលទ្ធផលរបស់កម្ពុជាធៀបនឹងប្រទេស SEAMEO ផ្សេងទៀត)។ តាមរយៈការអនុវត្តតាមវដ្តនៃតេស្តវាយតម្លៃនេះ ព័ត៌មានដែលទទួលបានអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើបច្ចុប្បន្នភាព និងតាមដានវឌ្ឍនភាពក្នុងរយៈពេលកន្លងមក។

### តេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ (ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១)

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានធានាគុណភាពអប់រំ (EQAD) ទទួលខុសត្រូវក្នុងការកសាងតេស្ត និងការគ្រប់គ្រងការអនុវត្ត (ដោយមានការគាំទ្រពីនាយកដ្ឋានផ្សេងៗដូចជា PED DCD TTD និង GSED) ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ ក៏ដូចជាការសរសេររបាយការណ៍ និងការផ្សព្វផ្សាយ។ រាល់ទិដ្ឋភាពទាំងអស់នៃការវាយតម្លៃនេះត្រូវបានអនុវត្តនៅកម្រិតថ្នាក់កណ្តាលនៃក្រសួងអប់រំ។

**ទិដ្ឋភាពទូទៅ៖** តេស្តវាយតម្លៃទាំងអស់នេះគឺជាការវាយតម្លៃដែលធ្វើការវិភាគលើសំណាកថ្នាក់ជាតិ ទៅលើសមត្ថភាពរបស់សិស្សពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុករបស់កម្មវិធីសិក្សា និងមានស្តង់ដាច្បាស់លាស់។ ការរៀបចំសំណាកវិភាគបច្ចុប្បន្នត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យពីសាលា

រៀនរដ្ឋចំនួនប្រហែល ២០០ និងសាលាឯកជនចំនួន ៣០ (ដោយកំណត់យកសិស្ស ៣០ នាក់ក្នុងមួយសាលា)។ ទិន្នន័យត្រូវបានប្រមូលអំឡុងខែចុងក្រោយនៃឆ្នាំសិក្សា ហើយការអនុវត្តតេស្តវង្វាយតម្លៃត្រូវបានចំណាយពេលប្រហែលពីរថ្ងៃ។ ការវាយតម្លៃថ្នាក់ជាតិក៏បានអនុវត្តកាលពីមុនៗមកដែរសម្រាប់ថ្នាក់ទី៣ ទី៦ និងទី៨ ហើយថ្នាក់ទី១១ ទើបតែបញ្ចូលបន្ថែមកាលពីពេលថ្មីៗ ដូច្នេះ ធ្វើឱ្យការអនុវត្តតេស្តវង្វាយតម្លៃនីមួយៗមានវដ្តបួនឆ្នាំម្តង។

**ផលជះ/ការប្រើប្រាស់៖** ការវាយតម្លៃថ្នាក់ជាតិមានបំណងកំណត់រកកត្តា ដែលមានទំនាក់ទំនងឬជះឥទ្ធិពលទៅលើលទ្ធផលសិក្សារបស់សិស្ស សម្រាប់ផ្តល់ព័ត៌មានដល់គោលនយោបាយ ការអនុវត្តនិងចងក្រងជាឯកសារអប់រំផ្សេងៗ។ បន្ថែមលើនេះ ការវាយតម្លៃថ្នាក់ជាតិ ត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលពីនិន្នាការក្នុងរយៈពេលណាមួយ។ ការវាយតម្លៃថ្នាក់ទី៨ និងថ្នាក់ទី១១ ក៏មានបំណងផ្តល់នូវការវាស់វែងនៅក្នុងដំណាក់កាលត្រៀមលក្ខណៈប្រឡងថែមទៀតផង។ នាយកដ្ឋានធានាគុណភាពអប់រំ នឹងធ្វើការផ្សព្វផ្សាយលទ្ធផលដែលទទួលបាន ប៉ុន្តែអនុសាសន៍ និងការកែប្រែគោលនយោបាយផ្សេងៗនឹងស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានជំនាញផ្សេងទៀត។ ដើម្បីងាយស្រួលក្នុងការបកស្រាយ ការផ្សព្វផ្សាយគួរផ្តោតលើកម្រិតសមត្ថភាពរបស់សិស្សជាជាងលើពិន្ទុប្រៀបធៀប។

### តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង (EGRA)[1]

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋាន ធានាគុណភាពអបរំ ទទួលខុសត្រូវក្នុងការអភិវឌ្ឍសំណួរតេស្ត និងការគ្រប់គ្រងអនុវត្តតេស្ត (ដោយមានការជួយគាំទ្រពីនាយកដ្ឋានផ្សេងៗទៀតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា) ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ព្រមទាំងការផ្សព្វផ្សាយលទ្ធផលតេស្ត។

**ទិដ្ឋភាពទូទៅ៖** តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងធ្វើការវិភាគទៅលើខ្លឹមសារ និងកិច្ចការរងមួយចំនួនដែលទាក់ទងនឹងកម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូង (Early Grade Reading Assistance) ដែលបាននឹងកំពុងធ្វើនៅក្នុងកម្រិតថ្នាក់បឋមសិក្សាកម្រិតទាប (ពីថ្នាក់ទី១ដល់ទី៣)។ ការវាយតម្លៃនេះធ្វើលើសាលារៀនដែលជាសាលាសំណាករបស់តេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣។ ដូចនេះ តេស្តនេះនឹងត្រូវធ្វើឡើងជារៀងរាល់៤ឆ្នាំម្តង។ តេស្តនេះត្រូវចំណាយពេលប្រហែលពី១០ ទៅ ១៥ នាទីសម្រាប់សិស្សម្នាក់ដោយប្រើឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្តារបន្ទះ (ថេបប្លេត)។ ការវាយតម្លៃនេះ គឺជាការសម្របសម្រួល និងអនុវត្តដោយសម្របតាមកម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូង ដែលត្រូវបានបង្កើតឡើង និងអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០១៦។ ការវាយតម្លៃនេះ មានតួនាទីសម្រាប់ធ្វើការវិភាគវិនិច្ឆ័យ

---

[1] តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង ខុសពីកម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូង ដែលអនុវត្តដោយនាយកដ្ឋានបឋមសិក្សា។ តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងផ្តោតលើការវាយតម្លៃលើបំណិនមូលដ្ឋាននៃការអានភាសាខ្មែរ ចំណែកឯ កម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូងផ្តោតលើកអន្តរាគមន៍ផ្សេងៗដែលធ្វើយ៉ាងណាដើម្បីបង្កើនបំណិនទាំងនោះ។

លើប្រព័ន្ធអប់រំនៅកម្រិតបឋមសិក្សាកម្រិតទាប ដោយប្រើប្រាស់ឧបករណ៍ និងវិធានការណ៍វាស់ស្ទង់លើលទ្ធផលសិក្សារបស់សិស្ស ដែលមិនអាស្រ័យលើកម្មវិធីសិក្សា។

**ផលជះ/ការប្រើប្រាស់៖** តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងប្រើប្រាស់ដើម្បីកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗនៃបំណិនជាមូលដ្ឋានសម្រាប់ការអាន ទៅលើសំណាកតំណាងឱ្យទូទាំងប្រទេស។ តាមរយៈតេស្តនេះ អ្នកវាយតម្លៃអាចកំណត់បានពីព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសមត្ថភាពអានរបស់កុមារមុនពេលដែលពួកគេឆ្លងទៅកម្រិតបឋមសិក្សាកម្រិតខ្ពស់ ឬឆ្លងទៅកម្រិតថ្នាក់បន្ទាប់។

ប៉ុន្តែ ការអនុវត្តការតេស្តវង្វាយតម្លៃនេះត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួន។

> ***កំណត់សម្គាល់៖***
> *តេស្តវង្វាយតម្លៃនេះមានបំណងដើម្បីបំពេញបន្ថែមនូវចំណុចខ្វះចន្លោះនៃការកំណត់រកលទ្ធផលសិក្សាពាក់ព័ន្ធនឹងការអានមុនពេលឈានទៅកាន់បឋមសិក្សាកម្រិតខ្ពស់ ឬកម្រិតថ្នាក់បន្ទាប់។ តាមគ្រោងទុក តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងនេះ គួរតែត្រូវបានអនុវត្តទៅលើសំណាកសិស្សនៅបឋមសិក្សាកម្រិតទាបនៅក្នុងសាលាសំណាកដូចគ្នាទៅនឹង (ធ្វើក្នុងពេលវេលាតែមួយ) តេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ដែរ។ ដូច្នេះហើយ ការវាយតម្លៃនេះនឹងត្រូវធ្វើឡើងរៀងរាល់៩ឆ្នាំម្តងដូចតេស្តថ្នាក់ជាតិថ្នាក់ទី៣ដែរ។ ហើយតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងនេះ គួរផ្តោតសំខាន់លើខ្លឹមសារ ឬកិច្ចការរងផ្សេងៗដែលបានបញ្ចូលនិងអនុវត្តដោយ កម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូងនៅបឋមសិក្សាកម្រិតទាប (ដូចជា ការស្គាល់តួអក្សរ ការអានពាក្យ និងការអានអត្ថបទផ្សេងៗ) និងមិនគួរប្រើប្រាស់ពេលវេលាយូរដែលអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការធ្វើតេស្តឡើយ។ នាយកដ្ឋានធានាគុណភាពអប់រំអាចកំណត់យកកម្រិតថ្នាក់ណាមួយ(ទី១ ទី២ ឬទី៣) ប៉ុន្តែត្រូវមានហេតុផលដែលសមរម្យ និងទទួលយកបានដើម្បីអនុវត្តតេស្តវង្វាយតម្លៃនេះ ហើយនាយកដ្ឋានក៏ត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅក្នុងកាអនុវត្តរបៀបប្រមូលទិន្នន័យថ្មីដោយប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្តារបន្ទះ (ថេបប្លេត) នេះ។*

តេស្តនេះក៏នឹងត្រូវធ្វើឡើងដំណាលគ្នានឹងតេស្តថ្នាក់ជាតិថ្នាក់ទី៣ផងដែរ ដើម្បីសម្រួលក្នុងការប្រមូលទិន្នន័យ។ នាយកដ្ឋានដឹកនាំ ត្រូវធ្វើការផ្សព្វផ្សាយលទ្ធផលដែលបានពីការវាយតម្លៃនេះ ផ្សេងគ្នាពីការផ្សព្វផ្សាយលទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ ប៉ុន្តែត្រូវមានភាពពាក់ព័ន្ធ និងផលប៉ះពាល់ស្រដៀងគ្នា។

**តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង (EGMA)[2]**

[2] តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង ខុសពីកម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូង ដែលអនុវត្តដោយនាយកដ្ឋានបឋមសិក្សា។ តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងសង្កត់ធ្ងន់លើការវាយតម្លៃលើបំណិនគណិត

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋាន ធានាគុណភាពអបរំ ទទួលខុសត្រូវក្នុងការអភិវឌ្ឍសំណួរតេស្ត និងការគ្រប់គ្រងអនុវត្តតេស្ត (ក្រោមការជួយគាំទ្រពីនាយកដ្ឋានផ្សេងៗទៀតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា) ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ ព្រមទាំងការផ្សព្វផ្សាយលទ្ធផលតេស្ត។

**ទិដ្ឋភាពទូទៅ៖** តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងធ្វើការវិភាគទៅលើខ្លឹមសារ និងកិច្ចការរងមួយចំនួនដែលទាក់ទងនឹងកម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូង (Early Grade Mathematics Assistance) ដែលបាននឹងកំពុងធ្វើនៅក្នុងកម្រិតថ្នាក់បឋមសិក្សាកម្រិតទាប (ពីថ្នាក់ទី១ដល់ទី៣)។ ការវាយតម្លៃនេះធ្វើលើសាលារៀនដែលជាសាលាសំណាករបស់តេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣។ ដូចនេះ ការវាយតម្លៃនឹងត្រូវធ្វើឡើងជារៀងរាល់៤ឆ្នាំម្តង។ តេស្តនេះត្រូវចំណាយពេលប្រហែលពី១០ ទៅ ១៥ នាទីសម្រាប់សិស្សម្នាក់ដោយប្រើឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្តារបន្ទះ (ថេបប្លេត)។ ការវាយតម្លៃនេះ គឺជាការសម្របសម្រួល និងអនុវត្តដោយសម្របតាមកម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូង។ ការវាយតម្លៃនេះ មានតួនាទីសម្រាប់ធ្វើការវិភាគវិនិច្ឆ័យលើប្រព័ន្ធអប់រំនៅកម្រិតបឋមសិក្សាកម្រិតទាប ដោយប្រើប្រាស់ឧបករណ៍និងវិធានការណ៍វាស់ស្ទង់លើលទ្ធផលសិក្សារបស់សិស្ស ដែលមិនអាស្រ័យលើកម្មវិធីសិក្សា។

ប៉ុន្តែ ក្នុងការអនុវត្តការធ្វើតេស្តនេះ ត្រូវយកចិត្តទុកដាក់លើចំណុចមួយ ចំនួន។

*កំណត់សម្គាល់៖*

*តេស្តវង្វាយតម្លៃនេះមានបំណងដើម្បីបំពេញបន្ថែមនូវចំណុចខ្វះចន្លោះនៃការកំណត់រកលទ្ធផលសិក្សាពាក់ព័ន្ធនឹងគណិតវិទ្យារបស់កុមារមុនពេលដែលពួកគេឆ្លងទៅកាន់បឋមសិក្សាកម្រិតខ្ពស់ឬកម្រិតថ្នាក់បន្ទាប់។ តាមគ្រោងទុកតេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូននេះ គួរតែត្រូវបានអនុវត្តទៅលើសំណាកសិស្សនៅក្នុងសាលាសំណាកនៅបឋមសិក្សាកម្រិតទាបដែលដូចគ្នាទៅនឹង (ធ្វើក្នុងពេលវេលាតែមួយ) សាលាសំណាករបស់តេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ដែរ។ ហើយ តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងនេះ គួរផ្តោតសំខាន់លើខ្លឹមសារ ឬកិច្ចការរងផ្សេងៗដែលបានបញ្ចូល និងអនុវត្តដោយ កម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូងនៅបឋមសិក្សាកម្រិតទាប និងមិនគួរប្រើប្រាស់ពេលវេលាយូរដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការធ្វើតេស្តឡើយ។ នាយកដ្ឋានធានាគុណភាពអប់រំអាចកំណត់យកកម្រិតថ្នាក់ណាមួយ(ទី១ ទី២ ឬទី៣) ដើម្បីអនុវត្តតេស្តវង្វាយតម្លៃនេះ ប៉ុន្តែត្រូវមានហេតុផលដែលសមរម្យ និងអាចទទួលយកបាន។ ហើយនាយកដ្ឋានត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅក្នុងកាអនុវត្តរបៀបប្រមូលទិន្នន័យថ្មី ដោយប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្តារបន្ទះ (ថេបប្លេត) នេះ។*

---

វិទ្យាជាមូលដ្ឋាន ចំណែកឯ កម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូងផ្តោតលើអន្តរាគមន៍ផ្សេងៗដែលធ្វើយ៉ាងណាដើម្បីបង្កើនបំណិនទាំងនោះ។

**ផលជះ/ការប្រើប្រាស់៖** តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងប្រើប្រាស់ដើម្បីកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗនៃបំណិនគណិតវិទ្យាជាមូលដ្ឋាន ទៅលើសំណាកតំណាងឱ្យសិស្សទូទាំងប្រទេស។ តាមរយៈតេស្តនេះ អ្នកវាយតម្លៃអាចកំណត់បានពីព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងសមត្ថភាពគណិតវិទ្យារបស់កុមារមុនពេលដែលពួកគេឆ្លងទៅបឋមសិក្សាកម្រិតខ្ពស់ ឬឆ្លងទៅកម្រិតថ្នាក់បន្ទាប់។ តេស្តនេះក៏នឹងត្រូវធ្វើឡើងដំណាលគ្នានឹងតេស្តថ្នាក់ជាតិថ្នាក់ទី៣ផងដែរ ដើម្បីសម្រួលក្នុងការប្រមូលទិន្នន័យ។ នាយកដ្ឋាន ត្រូវធ្វើការផ្សព្វផ្សាយលទ្ធផលដែលទទួលបានពីការវាយតម្លៃនេះផ្សេងគ្នាពីការផ្សព្វផ្សាយលទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ ប៉ុន្តែត្រូវមានភាពពាក់ព័ន្ធ និងផលប៉ះពាល់ស្រដៀងគ្នា។

### ប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានកិច្ចការប្រឡង(DEA) មានភារៈកិច្ចត្រួតពិនិត្យរាល់ទិដ្ឋភាពទាំងអស់នៃការប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី១២ (ប៉ុន្តែ ការសរសេរ ការដាក់ពិន្ទុ ការវិភាគ ការអនុវត្ត ។ល។ ត្រូវការការចូលរួមពីបុគ្គលិកមកពីគ្រប់នាយកដ្ឋានទាំងអស់ និងគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ)។

**ទិដ្ឋភាពទូទៅ៖** ការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ ជាការប្រឡងរយៈពេល ០២ថ្ងៃ (អនុវត្តចំពោះក្រុមសិស្ស ២៥ នាក់ក្នុងមួយបន្ទប់ ដែលគ្រូបង្រៀនដើរតួនាទីជាមេប្រយោគ) ហើយការប្រឡងនេះគ្របដណ្តប់លើមុខវិជ្ជាចំនួន ០៧ របស់បណ្តុំមួយក្នុងចំណោមបណ្តុំទាំងពីរ គឺវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ សិស្សត្រូវបានដាក់ពិន្ទុទៅក្នុង ០៥ ចំណាត់ថ្នាក់ គឺ A, B, C, D, F (ដែល F គឺស្មើនឹងធ្លាក់)។ ដើម្បីចូលប្រឡងថ្នាក់ទី១២ បេក្ខជនត្រូវបំពេញតាមលក្ខណវិនិច្ឆ័យដូចគ្នានឹងការប្រឡងថ្នាក់ទី៩ដែរ ថែមទាំងបានប្រឡងជាប់ ការប្រឡងថ្នាក់ទី៩រួចរាល់ហើយ។

អ្នកដែលប្រឡងជាប់ នឹងទទួលបានវិញ្ញាបនបត្រ។

**ផលជះ/ការប្រើប្រាស់៖** ការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ គឺជាការប្រឡងបញ្ចប់ភូមិសិក្សាទុតិយភូមិដែលមានស្តង់ដា ឬបទដ្ឋានច្បាស់លាស់។ បន្ថែមពីលើនេះ ការប្រឡងនេះត្រូវបានប្រើប្រាស់ក្នុងការសម្រេចចិត្តឱ្យសិស្សបន្តចូលសិក្សានៅថ្នាក់ឧត្តមសិក្សា (រួមទាំងការទទួលបានអាហារូបករណ៍ផងដែរ) ។ ការប្រឡងនេះសំខាន់ណាស់សម្រាប់ធ្វើការវិនិច្ឆ័យលើសមត្ថភាពរបស់សិស្សលើមុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សា ក៏ដូចជាលទ្ធផលសិក្សា។

### ៣.២.២. ការវាយតម្លៃផ្ទៃក្នុង

ជាការវាយតម្លៃដែលកើតមានជាលក្ខណៈផ្ទៃក្នុងនៅតាមសាលារៀន។ ដូច្នេះ ការវាយតម្លៃទាំងនេះត្រូវបានមូលមតិគ្នា (ប្រសិនបើអាចធ្វើបាន) អនុវត្តដោយបុគ្គលិកតាមសាលា។

ក. <u>ការវាយតម្លៃបញ្ចប់កម្រិតថ្នាក់ ឬភូមិសិក្សាកម្រិតសាលារៀន និងថ្នាក់រៀន៖</u> តាមនិយមន័យ ការវាយតម្លៃនេះមាន "អត្ថន័យ" ណាស់សម្រាប់សិស្ស ។ និយាយឱ្យចំជាង

នេះ លទ្ធផលពីការវាយតម្លៃទាំងអស់នេះ ត្រូវបានប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗលើឱកាសអប់រំរបស់សិស្ស (ឧទាហរណ៍ ការដាក់ឱ្យត្រួតថ្នាក់ ការដំឡើងថ្នាក់ ការបញ្ចប់ការសិក្សា។ល។)

ខ. <u>ការវាយតម្លៃតាមដំណាក់សម្រាប់អភិវឌ្ឍន៍កម្រិតសាលារៀន និងថ្នាក់រៀន៖</u> ជាការវាយតម្លៃដែលត្រូវបានដឹកនាំធ្វើដោយគ្រូបង្រៀនផ្ទាល់។ ការវាយតម្លៃទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យគ្រូនូវចំណេះដឹងចាំបាច់ ដើម្បីកែសម្រួលសកម្មភាពបង្រៀន និងរៀននៅក្នុងថ្នាក់ និងមានគោលដៅចុងក្រោយ គឺដើម្បីលើកកម្ពស់ លទ្ធផលសិក្សារបស់សិស្ស។

## ប្រឡងថ្នាក់ជាតិ ថ្នាក់ទី៩

**អ្នកដឹកនាំ៖** ការប្រឡងថ្នាក់ជាតិ ថ្នាក់ទី៩ គឺស្ថិតក្នុងដែនសមត្ថកិច្ចរបស់នាយកសាលា ប៉ុន្តែការត្រួតពិនិត្យត្រូវធ្វើឡើងនៅថ្នាក់ខេត្ត (ក្រោម GSED)។

**ទិដ្ឋភាពទូទៅ៖** ការប្រឡងថ្នាក់ទី៩ គឺជាការប្រឡងរយៈពេល ០២ថ្ងៃ។ ការប្រឡងនេះអនុវត្តចំពោះក្រុមសិស្ស ២៥ នាក់ក្នុងមួយបន្ទប់ ដែលគ្រូបង្រៀនដើរតួនាទីជាមេប្រយោគ។ គ្រប់មុខវិជ្ជាទាំងអស់ត្រូវបានយកមកប្រឡងនៅថ្នាក់ទី៩ ហើយសិស្សត្រូវបានដាក់ពិន្ទុទៅក្នុងកម្រិត ០៤ គឺក្រោមមធ្យម មធ្យម ល្អបង្គួរ និងល្អ ហើយសិស្សដែលត្រូវបានចាត់ថ្នាក់ថា "ក្រោមមធ្យម" ពួកគាត់មិនជាប់ការប្រឡងឡើយ។ ដើម្បីចូលរួមនៅក្នុងការប្រឡង បេក្ខជនត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យចំនួនបី៖ ប្រឡងជាប់ការវាយតម្លៃផ្សេងៗនៅក្នុងថ្នាក់ អវត្តមានមានច្បាប់តិចជាង ២០ដង និងជាប់ការវាយតម្លៃលើអាកប្បកិរិយារបស់គ្រូ។

អ្នកប្រឡងជាប់ នឹងទទួលបានវិញ្ញាបនបត្រ (សិស្សថ្នាក់ទី៩ ទទួលវិញ្ញាបនបត្រត្រឹមថ្នាក់ខេត្ត)។

**ផលជះ/ការប្រើប្រាស់៖** ជាការវាយតម្លៃដែលមានគោលដៅបម្រើឱ្យការប្រឡងចុងបញ្ចប់នៃវដ្តសិក្សា ឬបញ្ចប់ការអប់រំមូលដ្ឋាន ដើម្បីវាស់វែងពីការត្រៀមខ្លួនសម្រាប់បន្តទៅថ្នាក់ទី១០ ហើយការវាយតម្លៃនេះក៏ដើរតួជាតេស្តសម្រាប់ប្រឡងឡើងថ្នាក់ផងដែរ។ ការប្រឡងជាប់ការវាយតម្លៃនេះ ទើបអាចមានសិទ្ធិក្នុងការចូលរួមប្រឡងថ្នាក់ជាតិថ្នាក់ទី១២។

## ប្រឡងឡើងថ្នាក់ (ថ្នាក់ទី១ដល់ទី៥ ទី៧ ទី៨ ទី១០ និងទី១១)

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានបឋមសិក្សា (PED) ទទួលខុសត្រូវលើការផលិតរាល់ឯកសារណែនាំស្តីពីការប្រឡងឡើងថ្នាក់ពីថ្នាក់ទី១ ដល់ ទី៥ ។ ចំណែកឯ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED) ទទួលខុសត្រូវលើការណែនាំសម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ និង ទី១១។ នាយកសាលាទទួលខុសត្រូវក្នុងការបង្កើតតេស្តវង្វាយតម្លៃដោយខ្លួនឯង (តាមរយៈការណែនាំពី PED/GSED)។

**ទិដ្ឋភាពទូទៅ៖** ការប្រឡងឡើងថ្នាក់ជាការវាយតម្លៃដែលដឹកនាំដោយគ្រូ។ ការប្រឡងនេះត្រូវបានរៀបចំឡើងដើម្បីអនុវត្តចំពោះសិស្ស ដែលទទួលបានពិន្ទុជាមធ្យមក្រោម ៥០% នៃពិន្ទុប្រឡង

ប្រចាំឆមាសសរុបរបស់ខ្លួន។ វិសាលភាពនៃការវាយតម្លៃនេះ គឺសម្រាប់គ្រប់ថ្នាក់ទាំងអស់ លើកលែងតែថ្នាក់ចុងបំផុតភូមិសិក្សានីមួយៗ (បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ)។ ការវាយតម្លៃនេះ ត្រូវបានបង្កើតឡើងដោយនាយកសាលា និងអនុវត្តដោយគ្រូបង្រៀន។ ការប្រឡងនេះធ្វើតេស្តតែលើពីរមុខវិជ្ជាប៉ុណ្ណោះ គឺភាសាខ្មែរ និងគណិតវិទ្យា។ នៅកម្រិតបឋមសិក្សា ការប្រឡងឆមាសទី២ ត្រូវបានអនុវត្តនៅខែមិថុនាឬកក្កដា ហើយការប្រឡងឡើងថ្នាក់ត្រូវបានអនុវត្តនៅចុងខែសីហា (សម្រាប់សិស្សដែលធ្លាក់ការប្រឡងឆមាស) ។ ប្រសិនបើសិស្សប្រឡងមិនជាប់ គេនឹងមានឱកាសម្តងទៀតក្នុងការប្រឡងឡើងថ្នាក់នៅពេលចាប់ផ្តើមឆ្នាំសិក្សាបន្ទាប់។ នៅថ្នាក់មធ្យមសិក្សា ការប្រឡងឡើងថ្នាក់ ត្រូវបានអនុវត្តតែម្តងប៉ុណ្ណោះ (គឺនៅដើមឆ្នាំសិក្សាបន្ទាប់)។

**ផលជះ/ការប្រើប្រាស់៖** ការប្រឡងឡើងថ្នាក់ជាការផ្តល់ឱកាសទីពីរដល់សិស្ស។ ការប្រឡងនេះត្រូវបានអនុវត្តឡើង ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់។ ប្រសិនបើសិស្សប្រឡងជាប់ គេនឹងត្រូវបានអនុញ្ញាតឱ្យឡើងទៅថ្នាក់បន្ទាប់។ បរាជ័យក្នុងការប្រឡងឡើងថ្នាក់លើកទីពីរនេះ សិស្សនោះនឹងត្រូវរៀនត្រួតថ្នាក់។

ប៉ុន្តែ ការអនុវត្តការប្រឡងនេះត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួន។

> ***កំណត់ចំណាំ៖***
> *ទោះជាយ៉ាងណា សិស្សគួរទទួលបានឱកាសគ្រប់គ្រាន់ដើម្បីរៀន ឬហ្វឹកហាត់ ឬបណ្តុះបណ្តាលបន្ថែម ដើម្បីត្រៀមសម្រាប់ការប្រឡងឡើងថ្នាក់។ សំខាន់បំផុត ត្រូវផ្តល់គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការបង្កើតការវាយតម្លៃនេះ។ បច្ចុប្បន្ននេះ នៅពុំទាន់មានភាពច្បាស់លាស់ថាតើខ្លឹមសារនៃការវាយតម្លៃទាំងនេះត្រូវមានលក្ខណៈខុសគ្នាបែបណា ធៀបជាមួយនឹងខ្លឹមសារនៃការវាយតម្លៃប្រចាំឆមាស ហើយ/ឬ ថាតើខ្លឹមសារទាំងនោះត្រូវបានបង្កើតឡើង (ជាលក្ខណៈស្តង់ដា) តាមរបៀបណា ដើម្បីធានាថា ការវាយតម្លៃនោះពិតជាបានវាស់វែងសមស្របតាមលក្ខខណ្ឌសម្រាប់ការដំឡើងថ្នាក់។*

**ប្រឡងឆមាស (ថ្នាក់ទី១ដល់១២) និងអំណានស្ទាត់ (ថ្នាក់ទី៣និង៦)**

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (PED/DCD) ទទួលខុសត្រូវក្នុងការផ្តល់នូវគោលការណ៍ណែនាំទាំងមូលសម្រាប់ការវាយតម្លៃទាំងនេះនៅកម្រិតថ្នាក់បឋមសិក្សា ចំណែកឯ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED) មានតួនាទីណែនាំនៅកម្រិតថ្នាក់មធ្យមសិក្សា។ គ្រូទទួលខុសត្រូវលើការបង្កើតតេស្តវង្វាយតម្លៃនេះដោយខ្លួនឯង (បើទោះបីជាជួនកាល ការវាយតម្លៃទាំងនេះត្រូវបានបង្កើតឡើងនៅកម្រិតសាលារៀន ឬនៅកម្រិតកម្រងក្តី) ចំណែកឯ ការិយាល័យអប់រំស្រុក ដើរតួនាទីសំខាន់ក្នុងការណែនាំ និងការត្រួតពិនិត្យ។

**ទិដ្ឋភាពទូទៅ៖** ការវាយតម្លៃទាំងនេះកើតមានពីរដងក្នុងមួយឆ្នាំ (ប្រហែលនៅចុងឆមាសនីមួយៗ ដោយជំនួសឱ្យការវាយតម្លៃប្រចាំខែ នាខែនោះ) ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន

និងកីឡា។ ការវាយតម្លៃទាំងនេះត្រូវបានបង្កើតឡើង និងដឹកនាំដោយគ្រូបង្រៀន ដោយអនុវត្តតាមគោលការណ៍ណែនាំ ដែល PED និង GSED បានផ្តល់ជូន។ ការវាយតម្លៃទាំងនេះជាការវាយតម្លៃបញ្ចប់ ដែលត្រូវបានរៀបចំឡើងដើម្បីវាស់វែងថាតើ សិស្សបានរៀនចេះនូវអ្វី ដែលគ្រូបានបង្រៀនដែរឬទេ នៅក្នុងឆមាសទាំងពីរនៃឆ្នាំសិក្សានីមួយៗ។ ការវាយតម្លៃទាំងនេះត្រូវបានអនុវត្តនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់។ ដោយស្របតាមអនុសាសន៍ ការវាយតម្លៃលើអំណានស្ទាត់ ដែលជាសូចនាកររបស់នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ (M&E) សម្រាប់ថ្នាក់ទី៣ និងទី៦ ត្រូវបានធ្វើជាមួយគ្នានិងការប្រឡងឆមាសសម្រាប់នៅក្នុងកម្រិតថ្នាក់ទាំងពីរនេះ(សូមមើលរូបភាពទី៣)។

ប៉ុន្តែ ការអនុវត្តការប្រឡងនេះត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនផងដែរ។

***កំណត់ចំណាំ៖***

*ការវាយតម្លៃទាំងនេះ បច្ចុប្បន្នពុំមានស្តង់ដារូមនោះទេ ដោយសារតែការវាយតម្លៃនេះត្រូវបានបង្កើតដោយគ្រូឬសាលា (ថ្វីដ្បិតជួនកាល ពួកវាត្រូវបានអភិវឌ្ឍឡើងនៅកម្រិតកម្រងក្តី)។ ដូច្នេះ លទ្ធផលនៃការវាយតម្លៃទាំងនេះមិនអាចប្រៀបធៀបនឹងសាលាផ្សេងៗទៀតបានឡើយ ហើយមិនគួរយកទៅប្រើប្រាស់សម្រាប់របាយការណ៍ប្រៀបធៀបនោះទេ។ ការវាយតម្លៃទាំងនេះ យ៉ាងហោចណាស់គួរធ្វើឱ្យមានជាលក្ខណៈស្តង់ដារូម នៅថ្នាក់កម្រង/ថ្នាក់ស្រុក។ ធ្វើដូច្នេះ ការប្រៀបធៀបគ្នាក្នុងចំណោមសាលារៀននៅក្នុងស្រុកនឹងអាចធ្វើទៅបាន (ហើយក៏អនុញ្ញាតឱ្យមានការធ្វើវិមជ្ឈការក្នុងកម្រិតណាមួយផងដែរ)។*

*គោលការណ៍ណែនាំត្រូវតែផ្តល់ឱ្យបានច្បាស់លាស់ ទាក់ទងនឹងរបៀបបង្កើតសំណួរតេស្ត ដោយពុំចាំបាច់គិតដល់ថាតើការវាយតម្លៃទាំងនោះត្រូវបានបង្កើតឡើងក្នុងកម្រិតណានោះទេ។ ហើយសាលារៀនទាំងអស់ត្រូវទទួលបាននូវគោលការណ៍ណែនាំស្តីពីរបៀបអនុវត្តការវាយតម្លៃ។ ជាងនេះទៅទៀត* QEMIS *គួរធ្វើការប្រៀបធៀប (ពោលគឺផ្តល់មធ្យមភាគ នៅក្នុងរបាយការណ៍) ទៅតាមកម្រិតដែលការវាយតម្លៃនោះត្រូវបានធ្វើជាលក្ខណៈស្តង់ដារូម។*

*ជាចុងក្រោយ ជាអនុសាសន៍ អំណានស្ទាត់ដែលជាតម្រូវការ(ពិន្ទុ)ក្នុងការធ្វើរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡាបច្ចុប្បន្ន ត្រូវច្របាច់បញ្ចូលគ្នាជាមួយនឹងការប្រឡងឆមាស។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយ ពីការធ្វើរបាយការណ៍ប្រចាំត្រីមាស ទៅជាការធ្វើរបាយការណ៍ប្រចាំឆមាសវិញ និងជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យឱ្យកាន់តែមានប្រសិទ្ធភាព។ ហើយព័ត៌មានទទួលបានពីការវាយតម្លៃលើអំណានស្ទាត់នេះ (ដែលអនុវត្តចំពោះគ្រប់សិស្សនៅថ្នាក់ទី៣និងទី៦) នឹងអាចយកទៅប្រើប្រាស់សម្រាប់ជាគោលបំណងអភិវឌ្ឍសិក្សារបស់សិស្សផង (ជាពិសេស ក្រោយពេលឆមាសទីមួយ) និងដើម្បីបំពេញតាមលក្ខខណ្ឌសូចនាកររបស់ថ្នាក់ជាតិផង។*

**ផលជះ/ការប្រើប្រាស់៖** ការវាយតម្លៃទាំងនេះជាការវាយតម្លៃបញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា ហើយពិន្ទុមធ្យមភាគរួមនៅចុងឆមាសទីមួយ និងនៅដំណាច់ឆ្នាំសិក្សា ត្រូវបានប្រើប្រាស់សម្រាប់ការសម្រេចចិត្តឱ្យត្រួតថ្នាក់ឬឡើងថ្នាក់។ ពិន្ទុតិចជាង ៥០% នៃពិន្ទុកំណត់ សិស្សនោះត្រូវបានតម្រូវឱ្យត្រួតថ្នាក់។ ពិន្ទុក៏ត្រូវបានប្រើប្រាស់ដោយនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ(EMIS) ដើម្បីបង្កើតរបាយការណ៍របស់សាលា និងកំណត់រកសាលាណាដែលកំពុងត្រូវការការគាំទ្របន្ថែមខ្លាំងជាងគេ។

**ការវាយតម្លៃកម្រិតមត្តេយ្យសិក្សា/ការត្រៀមលក្ខណៈចូលសាលា (មត្តេយ្យកម្រិតខ្ពស់ និងថ្នាក់ទី១)**

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានកុមារតូច (ECED) ទទួលខុសត្រូវលើរាល់ទិដ្ឋភាពទាំងអស់នៃការវាយតម្លៃថ្នាក់មត្តេយ្យ។ គ្រូថ្នាក់ទី១ នឹងទទួលខុសត្រូវលើការអនុវត្តការវាយតម្លៃចំពោះការត្រៀមលក្ខណៈរបស់សិស្សសម្រាប់ចូលសាលា។

**ទិដ្ឋភាពទូទៅ៖** ការវាយតម្លៃកម្រិតមត្តេយ្យសិក្សា ជាការវាស់ស្ទង់ដែលអនុវត្តបីដងក្នុងមួយឆ្នាំចំពោះកុមារអាយុ៥ឆ្នាំនៅថ្នាក់មត្តេយ្យកម្រិតខ្ពស់(នៅសាលាមត្តេយ្យរដ្ឋ)។ ការវាយតម្លៃនេះ មានបំណងពិនិត្យមើលលើសមត្ថភាពសិស្សកម្រិតមត្តេយ្យ (និងវឌ្ឍនភាពធៀបនឹងលទ្ធផលរំពឹងទុកនៅកម្រិតមត្តេយ្យសិក្សា)។ ការវាយតម្លៃនេះអនុវត្តនៅដើម ពាក់កណ្ដាល និងចុងឆ្នាំសិក្សានីមួយៗ។ ការវាយតម្លៃនេះមានសូចនាករចំនួន១៨ ចែកជា៥ផ្នែក៖ រាងកាយ/សុខភាព ការរៀនសូត្រផ្នែកផ្លូវចិត្តនិងសង្គម (SEL) សីលធម៌/វប្បធម៌ ភាសា និងការគិត។ សូចនាករទាំងនោះ គឺស្របតាមកម្មវិធីសិក្សា ហើយត្រូវបានអភិវឌ្ឍឡើងដោយក្រសួងអប់រំ យុវជន និងកីឡាតាមរយៈការគាំទ្រពីអង្គការយូនីសេហ្វ (UNICEF)។ ការវាយតម្លៃនេះ ត្រូវបានអនុវត្តទៅលើសិស្សជាលក្ខណៈបុគ្គល ដែលមានរយៈពេលនៃការអនុវត្តចាប់ពី ១០ ទៅ ២០ នាទីសម្រាប់សិស្សម្នាក់។ ការវាយតម្លៃនេះជាការវាយតម្លៃដែលមិនមានលក្ខណៈវិនិច្ឆ័យជាប់ឬធ្លាក់ ហើយក៏មិនទាក់ទងនឹងការសម្រេចចិត្តចំពោះការដំឡើងថ្នាក់របស់សិស្សដែរ (ដោយសារតែសិស្សទាំងអស់ត្រូវបានដំឡើងថ្នាក់ ដោយពុំគិតពីសមត្ថភាពរបស់ពួកគេនោះទេ)។ ជាងនេះទៅទៀត លទ្ធផលដែលបានមកពីការអនុវត្តចុងក្រោយនៃការវាយតម្លៃនេះ អាចយកទៅប្រើប្រាស់ជារង្វាស់រង្វាលលើការត្រៀមលក្ខណៈចូលសាលាបាន។ ***សម្រាប់សិស្សដែលមិនបានចូលរៀននៅសាលាមត្តេយ្យរដ្ឋ ការវាយតម្លៃនេះអាចអនុវត្តទៅលើពួកគេនៅពេលចាប់ផ្ដើមថ្នាក់ទី១ ដើម្បីវាយតម្លៃពីការត្រៀមលក្ខណៈរបស់ពួកគេនៅដើមឆ្នាំសិក្សា។***

**ផលជះ/ការប្រើប្រាស់៖** ក្រៅពីការផ្ដល់នូវព័ត៌មានអំឡុងពេលសិក្សាស្ដីពីវឌ្ឍនភាពរបស់សិស្សនៅឆ្នាំចុងក្រោយនៃកម្រិតមត្តេយ្យសិក្សា ការវាយតម្លៃនេះក៏ដើរតួជាការវាស់វែងដែលចាំបាច់ទៅលើការត្រៀមលក្ខណៈចូលសាលារបស់សិស្ស (ដែលអនុវត្តនៅចុងបញ្ចប់នៃថ្នាក់មត្តេយ្យសិក្សា ឬនៅពេលចាប់ផ្ដើមថ្នាក់ទី១) ។

ប៉ុន្តែ ការអនុវត្តការវាយតម្លៃនេះត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួន។

*កំណត់ចំណាំ៖*

*ទោះជាយ៉ាងណា គ្រូបង្រៀននៅតែបានទទួលការបណ្តុះបណ្តាលតិចតួចទាក់ទងនឹងរបៀបប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះ ដើម្បីកែលម្អការបង្រៀននៅកម្រិតមត្តេយ្យសិក្សា។ ជាងនេះទៅទៀត លទ្ធផលបានមកពីការវាយតម្លៃនៅចុងឆ្នាំសិក្សា បច្ចុប្បន្ន ពុំត្រូវបានផ្តល់ទៅឱ្យគ្រូថ្នាក់ទី១ទេ (ពោលគឺ លទ្ធផលមិនបានបញ្ជូនទៅជាមួយនឹងសិស្សដែលចូលរៀនថ្នាក់បឋមសិក្សាឡើយ)។ ដូច្នេះ តម្លៃនៃការវាយតម្លៃនេះនឹងប្រសើរឡើង តាមរយៈការផ្តល់ឱ្យគ្រូបង្រៀននូវការបណ្តុះបណ្តាលបន្ថែម ស្តីពីការអនុវត្តការវាយតម្លៃ និងការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះ។ បន្ថែមលើនេះ លទ្ធផលទាំងនេះគួរត្រូវបានបញ្ចូលទៅក្នុងប្រវត្តិសិក្សារបស់សិស្ស ហើយផ្តល់ទៅឱ្យសាលាបឋមសិក្សាបន្ទាប់ពីឆ្លងភូមិសិក្សា។ ដោយសារតែក្រសួងអប់រំ យុវជន និងកីឡា មានការគ្រប់គ្រងតែលើសាលារដ្ឋ ដូច្នេះ ការលើកឡើងនេះ មិនត្រូវបានធានាថា នឹងត្រូវយកទៅអនុវត្តនៅតាមមត្តេយ្យឯកជន និង/ឬមត្តេយ្យសហគមន៍ឡើយ។ សម្រាប់សិស្សដែលមិនចូលរៀននៅមត្តេយ្យរដ្ឋ ការវាយតម្លៃនេះនឹងត្រូវអនុវត្តនៅពេលចាប់ផ្តើមថ្នាក់ទី១ (ដែលដូច្នេះ ហើយទើបតម្រូវឱ្យមានការផ្តល់វគ្គបណ្តុះបណ្តាល និងការណែនាំសម្រាប់គ្រូថ្នាក់ទី១)។*

**ប្រឡងប្រចាំខែ (ថ្នាក់ទី១ដល់១២)**

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានបឋមសិក្សា (PED) និង នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (DCD) ទទួលខុសត្រូវរួមគ្នាក្នុងការបង្កើតគោលការណ៍ណែនាំ និងរបៀបនៃការអនុវត្តរបស់ការវាយតម្លៃនេះនៅកម្រិតបឋមសិក្សា ប៉ុន្តែតេស្តវង្វាយតម្លៃត្រូវបានអភិវឌ្ឍ និងអនុវត្តដោយគ្រូបង្រៀន។ សម្រាប់ថ្នាក់មធ្យមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED) ទទួលខុសត្រូវលើគោលការណ៍ណែនាំ និងការត្រួតពិនិត្យ។

**ទិដ្ឋភាពទូទៅ៖** ការប្រឡងប្រចាំខែ ជាការវាយតម្លៃដែលដឹកនាំដោយគ្រូបង្រៀនផ្ទាល់។ ការវាយតម្លៃនេះតម្រូវឱ្យលោកគ្រូអ្នកគ្រូអនុវត្តជាប្រចាំខែ (នៅគ្រប់ខែទាំងអស់ លើកលែងតែខែដែលត្រូវប្រឡងឆមាស)។ ការវាយតម្លៃនេះត្រូវអនុវត្តចំពោះសិស្សគ្រប់រូប ដើម្បីកំណត់ថាតើ សិស្សបានយល់នូវខ្លឹមសារ ដែលពួកគេបានរៀនឬអត់។ ការវាយតម្លៃទាំងនេះត្រូវបានប្រើប្រាស់សម្រាប់គ្រប់មុខវិជ្ជាទាំងអស់។ ពុំមានទម្រង់បែបបទច្បាស់លាស់ ឬគោលការណ៍ណែនាំច្បាស់លាស់ថាតើ តេស្តវង្វាយ

តម្លៃទាំងនេះគួរមានសណ្ឋានដូចម្ដេចនោះទេ ប៉ុន្តែជាការរំពឹង គ្រប់មេរៀនទាំងអស់នឹងត្រូវត្រួតពិនិត្យ/វាយតម្លៃឡើងវិញ។

**ផលជះ/ការប្រើប្រាស់៖** "ការវាយតម្លៃ" ទាំងនេះ គួរយកទៅប្រើប្រាស់ក្នុងគោលបំណងដើម្បីអភិវឌ្ឍការសិក្សារបស់សិស្ស (ពោលគឺដើម្បីស្វែងយល់ពីការសិក្សារបស់សិស្ស និងដើម្បីកែលម្អការបង្រៀន)។ ការវាយតម្លៃទាំងនេះមានតម្លៃសម្រាប់កំណត់រកសិស្សខ្លាំង និងសិស្សខ្សោយ ដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរថាតើត្រូវផ្ដោតលើតម្រូវការខុសៗគ្នារបស់សិស្សនៅក្នុងថ្នាក់រៀនតាមរបៀបណា។ ជារឿងសំខាន់ ដែលគ្រូមានការយល់ដឹងច្បាស់លាស់ពីរបៀបដែលតេស្តវង្វាយតម្លៃនេះត្រូវបានបង្កើតឡើង និងការប្រើប្រាស់លើទិន្នន័យទទួលបានទាំងនេះ។ ប្រសិនបើគ្មានការណែនាំច្បាស់លាស់អំពីការវាយតម្លៃនេះទេ នោះគោលបំណងនៃការវាយតម្លៃនឹងនៅមានដែនកំណត់តូចចង្អៀតខ្លាំង។

## ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀន

**នាយកដ្ឋានដឹកនាំ៖** នាយកដ្ឋានបឋមសិក្សា (PED) និង នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (DCD) ទទួលខុសត្រូវរួមគ្នាលើការអភិវឌ្ឍគោលការណ៍ណែនាំ និងរបៀបនៃការអនុវត្តការវាយតម្លៃនេះនៅកម្រិតបឋមសិក្សា ប៉ុន្តែតេស្តវង្វាយតម្លៃត្រូវបានអភិវឌ្ឍ និងអនុវត្តដោយគ្រូបង្រៀន។ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED) ទទួលខុសត្រូវលើគោលការណ៍ណែនាំ និងការត្រួតពិនិត្យនៅកម្រិតថ្នាក់មធ្យមសិក្សា។

**ទិដ្ឋភាពទូទៅ៖** ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀនត្រូវបានធ្វើឡើងដោយគ្រូទាំងអស់ និងតម្រូវឱ្យអនុវត្តជាប្រចាំ។ តាមរយៈការវាយតម្លៃនេះ គ្រូអាចវាស់វែងបានទៀងទាត់ចំពោះការសិក្សា និងវឌ្ឍនភាពរបស់សិស្សធៀបទៅនឹងលទ្ធផលសិក្សា។ ហើយការវាយតម្លៃនេះដែរ គួរតែត្រូវបានអនុវត្តជា ដំណាក់ៗដើម្បីធ្វើការអភិវឌ្ឍការសិក្សារបស់សិស្សតាមដែលអាចធ្វើទៅបាន។ ការវាយតម្លៃនេះត្រូវបានអនុវត្តក្នុងលក្ខណៈក្រៅផ្លូវការ នៅគ្រប់មេរៀន ដូចជាចំណោទសួរ លំហាត់ធ្វើនៅផ្ទះ ការពិភាក្សាជាក្រុម គម្រោងស្រាវជ្រាវតូចៗ កិច្ចការដោះស្រាយបញ្ហា។ល។ គ្រូគួរទទួលបានការណែនាំ លើការបង្កើតនិងប្រើប្រាស់ឧបករណ៍វាយតម្លៃតាមដំណាក់ជាក់ស្ដែងផ្សេងៗ ដើម្បីធានាថា សិស្សកំពុងរៀនពីវិធី និងសកម្មភាពបង្រៀនដែលជឿនលឿន និងមានភាពពាក់ព័ន្ធជាងមុន។

**ផលជះ/ការប្រើប្រាស់៖** ការវាយតម្លៃនេះ គឺមានតម្លៃខ្លាំងណាស់ មិនត្រឹមតែសម្រាប់កំណត់រកសិស្សខ្លាំង និងសិស្សរៀនយឺត ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់លើតម្រូវការខុសៗគ្នារបស់សិស្សនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានតម្លៃក្នុងការធ្វើឱ្យមានសកម្មភាពចម្រុះនៅក្នុងថ្នាក់រៀន ដើម្បីលើកកម្ពស់វប្បធម៌រៀនសូត្រដែលសកម្ម និងឯករាជ្យរបស់សិស្សផងដែរ។ គ្រូគួរទទួលបានការបណ្ដុះបណ្ដាលគរុកោសល្យបន្ថែម ក៏ដូចជាការណែនាំជាលាយលក្ខណ៍អក្សរស្ដីពីរបៀបអនុវត្តការវាយតម្លៃជាប្រចាំតាមដំណាក់នៅថ្នាក់រៀន។ ជាងនេះទៅទៀត គ្រូគួរតែទទួលបានការណែនាំ ដើម្បីមានលទ្ធភាពអាចប្រើប្រាស់ឧបករណ៍វាយតម្លៃផ្សេងៗខុសៗគ្នានៅក្នុងអំឡុងការបង្រៀនក្នុងថ្នាក់។ ការ

ដាក់បញ្ចូលការវាយតម្លៃនេះទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និងកម្មវិធីវិក្រិតការគ្រូបង្រៀន បានផ្តល់តម្លៃបន្ថែមក្នុងការពង្រឹងការវាយតម្លៃកម្រិតថ្នាក់រៀនក្នុងរយៈពេលវែង។

## ៣.៣. ដំណើរការធ្វើសុខដុមនីយកម្ម

ការធ្វើសុខដុមនីយកម្មទៅលើការវាយតម្លៃ ជាដំណើរមួយដែលចាំបាច់ ដើម្បីធានាថាការវាយតម្លៃគ្រប់ប្រភេទទាំងអស់ត្រូវបានធ្វើទៅតាមគោលបំណងដែលបានកំណត់ ហើយក្នុងពេលជាមួយគ្នានោះដែរ ស្ថាប័នអនុវត្តគ្រប់កម្រិតទាំងអស់ត្រូវបានតម្រូវឱ្យអនុវត្តតួនាទីគាំទ្រ ឬពិនិត្យតាមដានដូចដែលបានរៀបរាប់ខាងក្រោមនេះ ដើម្បីធានាថា លទ្ធផលនៃការវាយតម្លៃ មានប្រយោជន៍សម្រាប់ឆ្លុះបញ្ចាំងទៅលើការសិក្សារបស់សិស្សនៅក្នុងថ្នាក់ សាលារៀន និងនៅកម្រិតប្រព័ន្ធ។

*តារាងទី 3. ដំណើរការធ្វើសុខដុមនីយកម្ម*

| ស្រទាប់ | ការវាយតម្លៃ | អង្គភាពអនុវត្ត | ដំណើរការសុខដុមនីយកម្ម | ផ្សេងៗ/មតិយោបល់ |
|---|---|---|---|---|
| ផ្ទៃក្រៅ | ការវាយតម្លៃកម្រិតអន្តរជាតិ និងថ្នាក់តំបន់ | EQAD | បន្តអនុវត្ត | EQAD ត្រូវធ្វើសមាហរណកម្មបទពិសោធន៍ពីការវាយតម្លៃសិស្សនៅកម្រិតអន្តរជាតិ និងថ្នាក់តំបន់ទៅក្នុងបរិបទជាតិនៃការវាយតម្លៃសិស្ស |
| | តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ | | បន្តអនុវត្ត | EQAD បន្តឆ្លុះបញ្ចាំងពីចំណុចខ្វះចន្លោះនៅក្នុងកម្មវិធីសិក្សា ការបង្រៀន ការរៀន និងការវាយតម្លៃសិស្ស ធ្វើយ៉ាងណាដើម្បីលើកកម្ពស់ទម្លាប់អនុវត្តរបស់នាយកដ្ឋានបច្ចេកទេសដែលពាក់ព័ន្ធ។ |
| | តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង | | <u>**បន្ថែម ប៉ុន្តែ**</u> EQAD ត្រូវធ្វើការជាមួយPED ដើម្បីកំណត់ពីគោលបំណងនៃការធ្វើការវាយតម្លៃនេះនិងធ្វើ | EQAD ចាប់ផ្តើមអនុវត្តរបៀបប្រមូលទិន្នន័យបែបថ្មីដោយប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្តារបន្ទះ (ថេបប្លេត)។ EQAD ត្រូវ |

| | | | | |
|---|---|---|---|---|
| | | | យ៉ាងណាឱ្យស្របគ្នាជាមួយកម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូង។ | ពិចារណាលើកម្រិតថ្នាក់ដែលត្រូវអនុវត្តការវាយតម្លៃនេះថានៅកម្រិតថ្នាក់ណាមួយ (ទី១ ឬទី២ ឬទី៣) ជាមួយនឹងហេតុផលសមរម្យ។ |
| | តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង | | **បន្ថែម ប៉ុន្តែ**<br>EQAD ត្រូវធ្វើការជាមួយPED ដើម្បីកំណត់ពីគោលបំណងនៃការធ្វើការវាយតម្លៃនេះនិងធ្វើយ៉ាងណាឱ្យស្របគ្នាជាមួយកម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូង។ | EQAD ចាប់ផ្ដើមអនុវត្តរបៀបប្រមូលទិន្នន័យបែបថ្មីដោយប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យកុំព្យូទ័រក្ដារបន្ទះទំនើប(ថេបប្លេត)។<br>EQAD ត្រូវពិចារណាលើកម្រិតថ្នាក់ដែលត្រូវអនុវត្តការវាយតម្លៃនេះថានៅកម្រិតថ្នាក់ណាមួយ (ទី១ ឬទី២ ឬទី៣) ជាមួយនឹងហេតុផលសមរម្យ។ |
| | ការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ | DEA | បន្តអនុវត្ត | DEA ត្រូវធានាថាលទ្ធផលសិក្សារបស់សិស្សត្រូវបានវាស់វែងធៀបនឹងកម្មវិធីសិក្សាដែលចង់បាន និងបានអនុវត្ត។ |
| ផ្ទៃក្នុង | ការប្រឡងថ្នាក់ជាតិថ្នាក់ទី៩ | សាលារៀន | **បន្តអនុវត្ត ប៉ុន្តែ**<br>សាលារៀននីមួយៗត្រូវគោរពតាមគំរូលំហាត់ឱ្យបានខ្ជាប់ខ្ជួន។ | ការិ.ស្រុក និង មន្ទីរ មានតួនាទីត្រួតពិនិត្យតាមដាន ដើម្បីធានាថាសាលារៀននីមួយៗមានសមត្ថភាពអភិវឌ្ឍសំណួរតេស្តទៅតាមគំរូបែបបទដែលចង់បាន។<br><br>ការធ្វើជាលក្ខណៈ: ស្តង់ដារូម អាចត្រូវបាន |

| | | | | |
|---|---|---|---|---|
| | | | | ពិចារណានៅថ្នាក់ស្រុក ឬថ្នាក់ខេត្តទៅថ្ងៃខាងមុខ។ |
| | ប្រឡងឡើងថ្នាក់ | សាលារៀន | **<u>បន្តអនុវត្ត ប៉ុន្តែ</u>** ការិ.ស្រុក គួរសម្របសម្រួលឱ្យមានការអភិវឌ្ឍសំណួរតេស្តសម្រាប់ការប្រឡងឡើងថ្នាក់ឱ្យមានស្តង់ដាត្រឹមត្រូវ | នាយកសាលា និង ការិ.ស្រុក/ មន្ទីរ មានតួនាទីពិនិត្យតាមដានការងារនេះ។ |
| | ប្រឡងឆមាសនិងអំណានស្ទាត់ | សាលារៀន | **<u>បន្តអនុវត្ត ប៉ុន្តែ</u>** សាលារៀននីមួយៗត្រូវគោរពតាមគំរូលំហាត់ឱ្យបានខ្ជាប់ខ្ជួន។ | នាយកសាលា និង ការិ.ស្រុក/ មន្ទីរ មានតួនាទីពិនិត្យតាមដានការងារនេះ។<br>ការធ្វើជាលក្ខណ: ស្តង់ដារូម អាចត្រូវបានពិចារណានៅថ្នាក់ស្រុក ឬថ្នាក់ខេត្តទៅថ្ងៃខាងមុខ។ |
| | ការវាយតម្លៃកម្រិតមត្តេយ្យសិក្សា/ការត្រៀមលក្ខណ:ចូលសាលា | សាលារៀន | **<u>បន្តអនុវត្ត ប៉ុន្តែ</u>** សាលារៀននីមួយៗត្រូវគោរពតាមគំរូលំហាត់ឱ្យបានខ្ជាប់ខ្ជួន។<br>ការិ.ស្រុក គួរសម្របសម្រួលឱ្យមានការអភិវឌ្ឍនូវសំណួរតេស្តសម្រាប់ការវាយតម្លៃកម្រិតមត្តេយ្យសិក្សា/ការត្រៀមលក្ខណ:ចូលសាលាឱ្យមានស្តង់ដារូម | នាយកសាលា និង ការិ.ស្រុក/ មន្ទីរ ដោយសហការជាមួយនឹង នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានកុមារតូច មានតួនាទីពិនិត្យតាមដានការងារនេះ។ |
| | ប្រឡងប្រចាំខែ | គ្រូបង្រៀន | **<u>បន្តអនុវត្ត ប៉ុន្តែ</u>** កម្រងសាលារៀនត្រូវសម្របសម្រួលឱ្យ | នាយកសាលានិងការិ.ស្រុក/ មន្ទីរ មានតួនាទី |

| | | | | |
|---|---|---|---|---|
| | | | មានការអភិវឌ្ឍនូវសំណួរតេស្តសម្រាប់ការប្រឡងប្រចាំខែឱ្យមានស្តង់ដាត្រឹមត្រូវ | ពិនិត្យតាមដានការងារនេះ។ |
| | ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀន | គ្រូបង្រៀន | **<u>បន្ថែម ប៉ុន្តែ</u>** គ្រូបង្រៀនគួរធានាថាការបង្រៀនមេរៀននីមួយៗ ត្រូវបានវាយតម្លៃតាមរយៈ: ឧបករណ៍វាយតម្លៃតាមដំណាក់ ដោយធៀបទៅនឹងវត្ថុបំណងមេរៀន | DCD, នាយកសាលានិងការិ.ស្រុក មានតួនាទីពិនិត្យតាមដានការងារនេះ។ កម្រងសាលារៀនគួរពិភាក្សាជាប្រចាំលើការវាយតម្លៃតាមដំណាក់របស់គ្រូបង្រៀននៅក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំខែ។ |

## ៣.៤. កាលកំណត់ និងការអនុវត្តការវាយតម្លៃ

រូបភាពខាងក្រោមនេះបង្ហាញអំពីទិដ្ឋភាពទូទៅ នៃក្របខ័ណ្ឌវាយតម្លៃការសិក្សារបស់សិស្សទៅតាមកម្រិតថ្នាក់ និងខែនៃឆ្នាំសិក្សា។ រូបភាពនេះមានដាក់ពណ៌សម្គាល់ ទៅតាមប្រភេទនៃការវាយតម្លៃ ហើយផ្តល់នូវរូបភាពច្បាស់លាស់អំពីចំនួនដងដែលត្រូវអនុវត្ត និងគោលបំណងនៃការវាយតម្លៃនៅកម្រិតថ្នាក់នីមួយៗ ចាប់ពីមត្តេយ្យសិក្សារហូតដល់ថ្នាក់ទី១២។ ការវាយតម្លៃនៅក្នុងរូបភាព ដែលមាន**អក្សរដិត**ត្រូវបានអនុវត្តចំពោះសិស្សទាំងអស់ ។ សម្រាប់ការវាយតម្លៃសរសេរជា*អក្សរទ្រេត* ត្រូវបានអនុវត្តចំពោះសិស្សមួយចំនួន ដែលជាសំណាក (អាចជាសំណាកដែលត្រូវជ្រើសរើសដោយចៃដន្យ ដូចជាការវាយតម្លៃថ្នាក់ជាតិ ឬជាសំណាក់ដែលត្រូវបានជ្រើសរើសដោយគោលបំណងច្បាស់លាស់ ដូចជា ការប្រឡងឡើងថ្នាក់(ដែលអនុវត្តចំពោះសិស្សដែលប្រឈមនឹងការរៀនត្រួតថ្នាក់ប៉ុណ្ណោះ))។ គោលបំណងសំខាន់នៃរូបភាពនេះ គឺដើម្បីបង្ហាញជូនអំពីការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកនៃការវាយតម្លៃនានានៅក្នុងប្រព័ន្ធអប់រំ (ទៅតាមកម្រិតថ្នាក់) ហើយក៏បង្ហាញពីរបៀបដែលក្របខ័ណ្ឌនេះកាត់បន្ថយចំនួននៃការវាយតម្លៃដែលត្រូវបានអនុវត្តក្នុងពេល និង/ឬគោលបំណងស្រដៀងគ្នានៅក្នុងកម្រិតថ្នាក់តែមួយ។ ម្យ៉ាងវិញទៀត រូបភាពនេះបង្ហាញអំពីក្របខ័ណ្ឌវាយតម្លៃ ដែលមានប្រសិទ្ធភាព និងជួយបំពេញបន្ថែមគ្នាទៅវិញទៅមក ហើយកាត់បន្ថយនូវភាពច្រំដែល ក៏ដូចជាផ្តល់នូវពេលវេលាសម្រាប់ការបង្ហាត់បង្រៀនក្នុងកម្រិតសមស្របតាមដែលអាចធ្វើទៅបាន។

*រូបភាពទី 3: ការវាយតម្លៃការសិក្សារបស់សិស្សទៅតាមកម្រិតថ្នាក់ ចំនួនដង និងប្រភេទ*

ការវាយតម្លៃការសិក្សាសិស្សដែលបានស្នើឡើង

| | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|---|---|
| មត្តេយ្យសិក្សា | ថ្នាក់មត្តេយ្យ | | | ថ្នាក់មត្តេយ្យ | | | | | ថ្នាក់មត្តេយ្យ | |
| ថ្នាក់ទី១ | *ត្រៀមលក្ខណៈចូលសាលា* | | | | | | | | | |
| | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | | | | | | | | | *ប្រឡងឡើងថ្នាក់* |
| ថ្នាក់ទី២ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | *ប្រឡងឡើងថ្នាក់(ពីទី១)* | | | | | | | | | *ប្រឡងឡើងថ្នាក់* |
| ថ្នាក់ទី៣ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | | | | អំណានស្ទាត់ | | | | អំណានស្ទាត់ | |
| | *ប្រឡងឡើងថ្នាក់(ពីទី២)* | | | | | | | | | *ប្រឡងឡើងថ្នាក់* |
| | | | | | | | | | | *តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ EGRA និង EGMA (៨ឆ្នាំម្តង)* |

**សម្គាល់៖** អន្តរជាតិ/ថ្នាក់តំបន់ | ការវិនិច្ឆ័យលើប្រព័ន្ធ | បញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា | តាមដំណាក់កម្រិតថ្នាក់រៀន | ការពិនិត្យតាមដាន

ការវាយតម្លៃការសិក្សាសិស្សដែលបានស្នើឡើង

| | | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|---|---|---|
| ការវាយតម្លៃការសិក្សាសិស្សដែលបានស្នើឡើង | ថ្នាក់ទី៤ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | *ប្រឡងឡើងថ្នាក់(ពីទី៣)* | | | | | | | | | *ប្រឡងឡើងថ្នាក់* |
| | ថ្នាក់ទី៥ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | *ប្រឡងឡើងថ្នាក់(ពីទី៤)* | | | | | | | | | *ប្រឡងឡើងថ្នាក់* |
| | | | | | | | | | *វដ្ត SEA-PLM* | | |
| | ថ្នាក់ទី៦ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | | | | | អំណានស្ទាត់ | | | | អំណានស្ទាត់ | |
| | | *ប្រឡងឡើងថ្នាក់(ពីទី៥)* | | | | | | | | | |
| | | | | | | | | | | | *តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ (៤ឆ្នាំម្តង)* |

សម្គាល់៖ អន្តរជាតិ/ថ្នាក់តំបន់ | ការវិនិច្ឆ័យលើប្រព័ន្ធ | បញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា | តាមដំណាក់កម្រិតថ្នាក់រៀន | ការពិនិត្យតាមដាន

ការវាយតម្លៃការសិក្សាសិស្សរៀនបានឡើង

| | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ទី៧ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| ថ្នាក់ទី៨ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | *ប្រឡងឡើងថ្នាក់(ពីទី៧)* | | | | | | | | | |
| | | | | | | | | | | *តេស្តវាស់វែងតម្លៃថ្នាក់ជាតិ ថ្នាក់ទី៨ (៤ឆ្នាំម្តង)* |
| ថ្នាក់ទី៩ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | *ប្រឡងឡើងថ្នាក់(ពីទី៨)* | | | | | | | | | |
| | | | | | | | | | | ប្រឡងថ្នាក់ជាតិថ្នាក់ទី៩ |

សម្គាល់៖ អន្តរជាតិ/ថ្នាក់តំបន់ | ការវិនិច្ឆ័យលើប្រព័ន្ធ | បញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា | តាមដំណាក់កម្រិតថ្នាក់រៀន | ការពិនិត្យតាមដាន

| ការវាយតម្លៃការសិក្សាសិស្សដែលបានស្នើឡើង | | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ទី១០ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | | *វដ្ដ PISA* | | | | | | | | |
| | ថ្នាក់ទី១១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | *ប្រឡងឡើងថ្នាក់(ពីទី១០)* | | | | | | | | | |
| | | | | | | | | | | | *តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី១១ (៤ឆ្នាំម្តង)* |
| | ថ្នាក់ទី១២ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី១ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងប្រចាំខែ | ប្រឡងឆមាសទី២ | |
| | | *ប្រឡងឡើងថ្នាក់(ពីទី១១)* | | | | | | | | | |
| | | | | | | | | | | | ការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ |

**សម្គាល់៖** អន្តរជាតិ/ថ្នាក់តំបន់ | ការវិនិច្ឆ័យលើប្រព័ន្ធ | បញ្ចប់កម្រិតថ្នាក់ឬភូមិសិក្សា | តាមដំណាក់កម្រិតថ្នាក់រៀន | ការពិនិត្យតាមដាន

**សម្គាល់៖ ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀន** គឺជាដំណើរការវាយតម្លៃការសិក្សារបស់សិស្សជាបន្តបន្ទាប់ពេញមួយឆ្នាំសិក្សា ។ ជារឿយៗ ការវាយតម្លៃនេះត្រូវបានធ្វើឡើងក្នុងពេលបង្រៀន ដែលអាចជាតេស្តតូចៗ ឬជាសកម្មភាពវាយតម្លៃដើម្បីអភិវឌ្ឍការសិក្សារបស់សិស្សដែលមិនមែនជាតេស្ត។

## ៤. ការគ្រប់គ្រង និងត្រួតពិនិត្យគុណភាពការវាយតម្លៃ

ការដែលអាចធានាបានថា រាល់ការវាយតម្លៃទាំងអស់ដែលមានបញ្ចូលនៅក្នុងក្របខ័ណ្ឌនេះ ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ នោះជារឿងសំខាន់ជាងគេនិងចាំបាច់បំផុត។ ដូច្នេះ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព ភាពអាចអនុវត្តបាន និងផលជះ រាល់ការវាយតម្លៃត្រូវមានក្រុមប្រតិបត្តិដែលពោរពេញដោយសមត្ថភាព សៀវភៅណែនាំ និងសេចក្ដីណែនាំដែលច្បាស់លាស់និងអាចអនុវត្តបាន ក៏ដូចជាវិធានផ្សេងៗក្នុងការវាយតម្លៃ និងត្រួតពិនិត្យគុណភាព។ ធាតុទាំងអស់នេះអាចធាននូវការអភិវឌ្ឍ និងផលជះរបស់ក្របខ័ណ្ឌនេះបាន។

*រូបភាពទី 4: ធាតុផ្សំនៃការគ្រប់គ្រង និងត្រួតពិនិត្យលើការវាយតម្លៃ*




### ៤.១. ក្រុមប្រតិបត្តិការវាយតម្លៃ

**គោលការណ៍ទី១៖ ដើម្បីធានាឱ្យបាននូវការអនុវត្តការវាយតម្លៃដោយរលូន និងមានប្រសិទ្ធភាព ចាំបាច់ត្រូវបង្កើតក្រុមប្រតិបត្តិសម្រាប់ការវាយតម្លៃនីមួយៗ។**

*រូបភាពទី 5: រចនាសម្ព័ន្ធនៃក្រុមប្រតិបត្តិ*




ការវាយតម្លៃនីមួយៗត្រូវមានក្រុមការងារដើម្បីផ្ដល់ទិសដៅ ដឹកនាំ និងអនុវត្ត។ ជាទូទៅ ក្រុមប្រតិបត្តិនីមួយៗគួរមានបីកម្រិត៖ គណៈកម្មាធិការ/កម្មការគ្រប់គ្រងនិងដឹកនាំ គណៈកម្មាធិការ/កម្មការតាមដាននិងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស។ គណៈកម្មាធិការ/កម្មការនីមួយៗគួរមាន

សមាជិកដែលមានចំណេះដឹង និងការអនុវត្តខ្ពស់ផ្នែកការវាយតម្លៃ។

ដូចបានបញ្ជាក់ពីខាងលើ ការវាយតម្លៃទាំងអស់ត្រូវបានចាត់ថ្នាក់ជាពីរស្រទាប់សំខាន់ៗ គឺការវាយតម្លៃផ្ទៃក្រៅ (ពោលគឺ ការវាយតម្លៃទ្រង់ទ្រាយធំ) និងការវាយតម្លៃផ្ទៃក្នុង (ការវាយតម្លៃនៅកម្រិតសាលា និងថ្នាក់រៀន)។ ទាំងការវាយតម្លៃផ្ទៃក្រៅនិងផ្ទៃក្នុងគួរមានគណៈកម្មាធិការត្រឹមត្រូវដើម្បីពិនិត្យមើលរាល់ទិដ្ឋភាពនៃដំណើរការសម្រាប់ការវាយតម្លៃនីមួយៗ។ តែចូរចងចាំថា គណៈកម្មាធិការទាំងនេះគួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញក្នុងករណីចាំបាច់។ អាស្រ័យហេតុនេះ តួនាទី និងសមាសភាពនៃគណៈកម្មាធិការនីមួយៗ មានរៀបរាប់ដូចខាងក្រោមនេះ។

### ៤.១.១. ការវាយតម្លៃផ្ទៃក្រៅ

**១. គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ**

គណៈកម្មាធិការ/កម្មការគ្រប់គ្រងនិងដឹកនាំ មានទំនួលខុសត្រូវខ្ពស់បំផុតលើការងារគ្រប់គ្រង និងត្រួតពិនិត្យលើការវាយតម្លៃនីមួយៗ។ គណៈកម្មាធិការ/កម្មការនេះគួរមានសមាជិកដែលមានសមត្ថភាព និងការសម្រេចចិត្តខ្ពស់ និង មានលក្ខណៈចម្រុះ ដែលមានឋានៈ និងសារតាខុសៗគ្នាដោយយោងទៅតាមប្រភេទនៃការវាយតម្លៃ។

សមាសភាពរបស់គណៈកម្មាធិការ/កម្មការគ្រប់គ្រងនិងដឹកនាំសម្រាប់ការវាយតម្លៃផ្ទៃក្រៅ គួរតែជាថ្នាក់ដឹកនាំជាន់ខ្ពស់មកពីក្រសួងអប់រំ យុវជន និងកីឡា រួមមានរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គាធិការ អគ្គនាយករង ប្រធាននាយកដ្ឋានបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍។ តារាងខាងក្រោមនេះបង្ហាញពីសមាសភាពដែលបានលើកឡើងសម្រាប់ការពិចារណា។

*តារាងទី 4: សមាសភាពគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | រដ្ឋមន្ត្រី (ឬរដ្ឋលេខាធិការ) | ១ | ប្រធាន |
| ២ | រដ្ឋលេខាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ១ ទៅ ៣ | អនុប្រធាន |
| ៣ | អនុរដ្ឋលេខាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ១ ទៅ ៣ | សមាជិក |
| ៤ | អគ្គនាយក និងអគ្គាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ៣ ទៅ ៥ | សមាជិក |
| ៥ | អគ្គនាយករង និងអគ្គាធិការរង (ទទួលបន្ទុកការវាយតម្លៃ) | ៣ ទៅ ៥ | សមាជិក |
| ៦ | ប្រធាននាយកដ្ឋាន (ទទួលបន្ទុក និងពាក់ព័ន្ធនឹងការវាយតម្លៃ) | ៥ ទៅ ៨ | សមាជិក |
| ៧ | តំណាងដៃគូអភិវឌ្ឍន៍ | ៣ ទៅ ៥ | សមាជិក |

គណៈកម្មាធិការ/កម្មការនេះមានតួនាទីជាក់លាក់ដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យលើគណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេសទាក់ទងនឹងការវាយតម្លៃ

- ផ្តល់ការណែនាំដល់ក្រុមថ្នាក់ជាតិ និងក្រោមជាតិអំពីដំណើរការរបស់ការវាយតម្លៃ
- អភិវឌ្ឍគោលនយោបាយក្នុងការវាយតម្លៃ
- អនុម័តលើផែនការ និងគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ
- ពិនិត្យតាមដាន និងវាយតម្លៃលើដំណើរការវាយតម្លៃ
- ពង្រឹងនិងលើកទឹកចិត្តដល់គណៈកម្មាធិការតាមដាននិងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស
- ចូលរួមនៅក្នុងកិច្ចប្រជុំ ឬសន្និបាត (ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ) ទាក់ទងនឹងការវាយតម្លៃ
- កែលម្អដំណើរការវាយតម្លៃ
- បង្កើត និង/ឬ រំលាយអនុគណៈកម្មាធិការ/ក្រុម ប្រសិនបើចាំបាច់
- កោះហៅប្រជុំតាមភាពចាំបាច់

**២. គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស**

គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេសមានកាតព្វកិច្ចក្នុងការវាយការណ៍ជូនគណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ។ គណៈកម្មាធិការ/កម្មការនេះមានទំនួលខុសត្រូវខ្ពស់បំផុតកម្រិតទីពីរសម្រាប់ការវាយតម្លៃនីមួយៗ។ គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេសគួរមានសមាជិកដែលមានសមត្ថភាព និងការសម្រេចចិត្តខ្ពស់ និង មានលក្ខណៈចម្រុះដែលមានឋានៈ និងសាវតារខុសៗគ្នា ដោយយោងទៅតាមប្រភេទនៃការវាយតម្លៃ។

សមាសភាពរបស់គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្រៅ គួរតែជាថ្នាក់ដឹកនាំជាន់ខ្ពស់មកពីក្រសួងអប់រំ យុវជន និងកីឡា រួមមាន រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គាធិការ អគ្គនាយករង ប្រធាននាយកដ្ឋានបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍។ តារាងខាងក្រោមនេះបង្ហាញពីសមាសភាពដែលបានស្នើឡើងសម្រាប់ការពិចារណា។

*តារាងទី 5: សមាសភាពគណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេសការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | រដ្ឋលេខាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ១ | ប្រធាន |
| ២ | អនុរដ្ឋលេខាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ២ ទៅ ៥ | អនុប្រធាន |
| ៣ | អគ្គនាយក និងអគ្គាធិការ (ទទួលបន្ទុកការវាយតម្លៃ) | ២ ទៅ ៥ | សមាជិក |
| ៤ | សកលវិទ្យាធិការ | ១ ទៅ ៣ | សមាជិក |
| ៥ | អគ្គនាយករង និងអគ្គាធិការរង(ទទួលបន្ទុកការវាយតម្លៃ) | ២ ទៅ ៥ | សមាជិក |
| ៦ | ប្រធាននាយកដ្ឋាន (ទទួលបន្ទុក និងពាក់ព័ន្ធនឹងការវាយតម្លៃ) | ៣ ទៅ ៥ | សមាជិក |
| ៧ | តំណាងដៃគូអភិវឌ្ឍន៍ | ២ ទៅ ៥ | សមាជិក |

គណៈកម្មាធិការ/កម្មការនេះមានតួនាទីជាក់លាក់ដូចខាងក្រោម៖

- រាយការណ៍ពីវឌ្ឍនភាពនៃការវាយតម្លៃជូនទៅគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំ
- គ្រប់គ្រង និងត្រួតពិនិត្យលើក្រុមបច្ចេកទេស
- ដឹកនាំនិងគាំទ្រក្រុមបច្ចេកទេសក្នុងការអនុវត្តការវាយតម្លៃ
- ចូលរួមជាមួយនឹងក្រុមបច្ចេកទេសនៅក្នុងការកសាងផែនការ និងការរៀបចំគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ
- ពិនិត្យតាមដាន និងវាយតម្លៃលើដំណើរការវាយតម្លៃ
- កែលម្អដំណើរការវាយតម្លៃ
- ពង្រឹង និងលើកទឹកចិត្តក្រុមបច្ចេកទេស
- ចូលរួមជាមួយនឹងគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំនៅក្នុងការបង្កើត និង/ឬការរំលាយ អនុគណៈកម្មាធិការ/ក្រុម ក្នុងករណីចាំបាច់
- ចូលរួមនៅក្នុងកិច្ចប្រជុំ ឬសន្និបាត (ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ) ទាក់ទងនឹងការវាយតម្លៃ
- អនុវត្តតាមការណែនាំពីគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំ
- កោះហៅប្រជុំតាមភាពចាំបាច់

**៣. ក្រុមបច្ចេកទេស**

ក្រុមបច្ចេកទេសមានទំនួលខុសត្រូវចំបងនិងផ្ទាល់លើការវាយតម្លៃនីមួយៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការដឹកនាំ និងការអនុវត្តការវាយតម្លៃផ្ទាល់។ ដូច្នេះ ក្រុមការងារនេះត្រូវតែបង្កើតឡើងដោយប្រុងប្រយ័ត្ន ហើយសមាជិកត្រូវមានជំនាញច្បាស់លាស់លើផ្នែកវាយតម្លៃ និងសារតាខុសៗគ្នាទៅតាមប្រភេទនៃការវាយតម្លៃ។

សមាសភាពរបស់ក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្រៅ គួរតែជាថ្នាក់ដឹកនាំ និងមន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលមានជំនាញលើផ្នែកវាយតម្លៃ រួមមាន ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ មន្ត្រី និងក្រុមជំនួយមកពីនាយកដ្ឋានបច្ចេកទេស និងដៃគូអភិវឌ្ឍន៍។ តារាងខាងក្រោមនេះបង្ហាញពីបេក្ខជនដែលបានស្នើឡើងសម្រាប់ការពិចារណា។

*តារាងទី 6: សមាសភាពក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្រៅដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន (នាយកដ្ឋានជំនាញផ្នែកវាយតម្លៃ) | ១ | ប្រធាន |
| ២ | អនុប្រធាននាយកដ្ឋាន (នាយកដ្ឋានជំនាញផ្នែកវាយតម្លៃ) | ១ ទៅ ២ | អនុប្រធាន |
| ៣ | ប្រធានការិយាល័យ (ការិយាល័យជំនាញផ្នែកវាយតម្លៃ) | ១ ទៅ ៣ | សមាជិក |

| | | | |
|---|---|---|---|
| ៤ | អនុប្រធានការិយាល័យ (ការិយាល័យជំនាញផ្នែកវាយតម្លៃ) | ១ ទៅ ៣ | សមាជិក |
| ៥ | មន្ត្រី (ការិយាល័យជំនាញផ្នែកវាយតម្លៃ) | ៨ ទៅ ១៥ | សមាជិក |
| ៦ | តំណាងពីដៃគូអភិវឌ្ឍន៍ | ១ ទៅ ២ | សមាជិក |
| ៧ | ទីប្រឹក្សាជាតិ និង/ឬអន្តរជាតិ | ១ ទៅ ២ | សមាជិក |

ក្រុមបច្ចេកទេសមានតួនាទី និងទំនួលខុសត្រូវដូចខាងក្រោម៖

- រៀបចំដំណើរការវាយតម្លៃ
- បង្កើតឧបករណ៍សម្រាប់ការវាយតម្លៃ
- ដឹកនាំការងារប្រមូលទិន្នន័យ គ្រប់គ្រង់ទិន្នន័យ និងវិភាគទិន្នន័យ
- សរសេររបាយការណ៍
- ផ្សព្វផ្សាយលទ្ធផលដល់អ្នកពាក់ព័ន្ធ
- វាយការណ៍អំពីវឌ្ឍនភាពនៃការវាយតម្លៃជូនគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និង គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ
- រៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តការវាយតម្លៃ
- រៀបចំគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ
- ចូលរួមនៅក្នុងកិច្ចប្រជុំ ឬសន្និបាត (ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ) ទាក់ទងនឹងការវាយតម្លៃ
- ស្នើ និង/ឬចូលរួមនៅក្នុង ការបង្កើត និង/ឬការរំលាយ អនុគណៈកម្មាធិការ/កម្មការ/ក្រុម (ជាមួយនឹង គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ និងគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស) ក្នុងករណីចាំបាច់
- អភិវឌ្ឍសមត្ថភាពជាប្រចាំទាក់ទងនឹងការវាយតម្លៃ
- កែលម្អដំណើរការវាយតម្លៃ ក្នុងករណីចាំបាច់
- ស្នើសុំឱ្យមានកិច្ចប្រជុំ ក្នុងករណីចាំបាច់
- អនុវត្តរាល់ភារកិច្ចទាំងអស់ ដែលផ្តល់ដោយគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និង គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ

## ៤.១.២. ការវាយតម្លៃផ្ទៃក្នុង

### ១. គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ

គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំសម្រាប់ការវាយតម្លៃផ្ទៃក្នុង គួរមានសមាសភាពជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់រាជធានី/ខេត្ត រួមមានប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត (PoE) ប្រធានការិយាល័យបច្ចេកទេស ប្រធានការិយាល័យអប់រំស្រុក(DoE) ក្រុមបណ្តុះបណ្តាល និងពិនិត្យតាមដានថ្នាក់ស្រុក(DTMT) ប្រធានកម្រង នាយកសាលា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

*តារាងទី 7: សមាសភាពគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | ប្រធាន ឬអនុប្រធានមន្ទីរអប់រំខេត្ត (ទទួលបន្ទុកការងារវាយតម្លៃ) | ១ | ប្រធាន |
| ២ | ប្រធានការិយាល័យបច្ចេកទេសនៃមន្ទីរអប់រំខេត្ត ឬប្រធានការិយាល័យអប់រំស្រុក (ទទួលបន្ទុកការងារវាយតម្លៃ) | ១ ទៅ ២ | អនុប្រធាន |
| ៣ | មន្ត្រីក្នុងការិយាល័យអប់រំស្រុក | ១ ទៅ ២ | សមាជិក |
| ៤ | DTMT ឬប្រធានកម្រង | ១ ទៅ ៣ | សមាជិក |
| ៥ | នាយក ឬនាយករងសាលា | ១ | សមាជិក |
| ៦ | តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសហគមន៍ (ឬមកពីគណៈកម្មការគ្រប់គ្រងសាលា) | ១ ទៅ ៣ | សមាជិក |

គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្នុងមានតួនាទីជាក់លាក់ដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យលើគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេសទាក់ទងនឹងការវាយតម្លៃ
- ផ្តល់ការណែនាំដល់គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេសទាក់ទងនឹងការវាយតម្លៃ
- អនុម័តលើផែនការ និងគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ
- ពិនិត្យតាមដាន និងវាយតម្លៃលើដំណើរការវាយតម្លៃ
- ពង្រឹង និងលើកទឹកចិត្តដល់គណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស
- ចូលរួមក្នុងកិច្ចប្រជុំ ឬសន្និបាត (ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ) ទាក់ទងនឹងការវាយតម្លៃ
- កែលម្អដំណើរការវាយតម្លៃ
- បង្កើត និង/ឬ រំលាយអនុគណៈកម្មាធិការ/កម្មការ/ក្រុម ប្រសិនបើចាំបាច់
- អនុវត្តតាមការណែនាំរបស់គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំការវាយតម្លៃផ្ទៃក្រៅ
- កោះហៅប្រជុំ តាមភាពចាំបាច់

**២. គណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេស**

គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្នុង គួរមានសមាសភាពជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់រាជធានី/ខេត្ត រួមមានអនុប្រធានមន្ទីរអប់រំរាជធានី/ខេត្ត(PoE) ប្រធានឬមន្ត្រីការិយាល័យបច្ចេកទេស ប្រធានឬមន្ត្រីការិយាល័យអប់រំ ស្រុក(DoE) DTMT ប្រធានឬសមាជិកកម្រង នាយកសាលា ប្រធានក្រុមបច្ចេកទេស

តាមមុខវិជ្ជា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ តារាងខាងក្រោមនេះបង្ហាញពីសមាសភាពដែលបានស្នើឡើងសម្រាប់ការពិចារណា។

*តារាងទី 8: សមាសភាពគណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេសការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | អនុប្រធានមន្ទីរអប់រំរាជធានី/ខេត្ត (ទទួលបន្ទុកការងារវាយតម្លៃ) | ១ | ប្រធាន |
| ២ | មន្ត្រីពីការិយាល័យបច្ចេកទេស (ទទួលបន្ទុកការងារវាយតម្លៃ) | ១ ទៅ ២ | អនុប្រធាន |
| ៣ | មន្ត្រីមកពីការិយាល័យអប់រំស្រុក | ១ ទៅ ២ | សមាជិក |
| ៤ | DTMT ឬសមាជិករបស់កម្រង | ១ ទៅ ៣ | សមាជិក |
| ៥ | នាយកសាលា | ១ | សមាជិក |
| ៦ | ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា | ១ ទៅ ៣ | សមាជិក |
| ៧ | តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសហគមន៍ (ឬមកពីគណៈកម្មការគ្រប់គ្រងសាលា) | ២ ទៅ ៥ | សមាជិក |

គណៈកម្មាធិការ/កម្មការនេះមានតួនាទីជាក់លាក់ក្នុងការជួយគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមបច្ចេកទេសដូចខាងក្រោម៖

- រាយការណ៍អំពីវឌ្ឍនភាពនៃការវាយតម្លៃទៅឱ្យគណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ
- ត្រួតពិនិត្យ និងជួយក្រុមបច្ចេកទេស
- ណែនាំដល់ក្រុមបច្ចេកទេសក្នុងការអនុវត្តការវាយតម្លៃ
- ចូលរួមជាមួយក្រុមបច្ចេកទេសនៅក្នុងការធ្វើផែនការ និងរៀបចំគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ
- ពិនិត្យតាមដាន និងវាយតម្លៃលើដំណើរការវាយតម្លៃ
- ពង្រឹង និងលើកទឹកចិត្តក្រុមបច្ចេកទេស
- ចូលរួមជាមួយគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំនៅក្នុងការបង្កើត និង/ឬ រំលាយអនុគណៈកម្មាធិការ/កម្មការ/ក្រុម ក្នុងករណីចាំបាច់
- កែលម្អដំណើរការវាយតម្លៃ
- អនុវត្តតាមការណែនាំរបស់គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ និងគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេសទទួលបន្ទុកការវាយតម្លៃផ្ទៃក្រៅ
- កោះហៅប្រជុំ តាមភាពចាំបាច់

**៣. ក្រុមបច្ចេកទេស**

ក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្នុងគួរមានសមាសភាពជាថ្នាក់ដឹកនាំ និងមន្ត្រីមកពីមន្ទីរអប់រំរាជធានី/ខេត្ត ដែលមានជំនាញលើផ្នែកវាយតម្លៃ រួមមាន ប្រធានមន្ទីរ អនុប្រធានមន្ទីរ ប្រធានការិយាល័យ អនុប្រធានការិយាល័យ មន្ត្រី នាយកសាលា និងគ្រូតាមមុខវិជ្ជាមកពីរាជធានី/ខេត្ត ស្រុក និងសាលានីមួយៗ។ តារាងខាងក្រោមនេះ បង្ហាញពីសមាសភាពដែលបានស្នើឡើងសម្រាប់ការពិចារណា៖

*តារាងទី ១: សមាសភាពក្រុមបច្ចេកទេសសម្រាប់ការវាយតម្លៃផ្ទៃក្នុងដែលបានស្នើឡើង*

| ល.រ | សមាសភាព | ចំនួន | តួនាទី |
|---|---|---|---|
| ១ | ប្រធានមន្ទីរអប់រំខេត្ត ឬនាយកសាលា | ១ | ប្រធាន |
| ២ | អនុប្រធានមន្ទីរ ឬប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា | ១ ទៅ ២ | អនុប្រធាន |
| ៣ | មន្ត្រីមកពីមន្ទីរអប់រំរាជធានី/ខេត្ត (មកពីការិយាល័យជំនាញ) ឬគ្រូតាមមុខវិជ្ជា | ១ ទៅ ១១ | សមាជិក |
| ៤ | មន្ត្រីការិយាល័យអប់រំស្រុក | ១ ទៅ ៣ | សមាជិក |
| ៥ | សមាជិករបស់កម្រង | ១ ទៅ ២ | សមាជិក |
| ៦ | តំណាងសហគមន៍ (ឬពីគណៈកម្មការគ្រប់គ្រងសាលា) | ១ ទៅ ២ | សមាជិក |

ក្រុមបច្ចេកទេសនេះគួរត្រូវបានបង្កើតឡើងទៅតាមការវាយតម្លៃ។ សម្រាប់ការវាយតម្លៃនៅកម្រិតសាលា (ឧទាហរណ៍ ការប្រឡងប្រចាំខែ។ល។) ក្រុមបច្ចេកទេសគួរមាន

សមាសភាពជានាយកសាលា សមាជិកកម្រង ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា គ្រូបង្រៀនតាមមុខវិជ្ជា និងតំណាងមកពីសហគមន៍ (ឬមកពីគណៈកម្មការគ្រប់គ្រងសាលា)។

ក្រុមបច្ចេកទេស មានតួនាទីជាក់លាក់ដូចខាងក្រោម៖

- រៀបចំដំណើរការវាយតម្លៃ
- អភិវឌ្ឍឧបករណ៍សម្រាប់ការវាយតម្លៃ
- អនុវត្តការវាយតម្លៃ
- សរសេររបាយការណ៍
- ផ្សព្វផ្សាយលទ្ធផល
- រាយការណ៍អំពីវឌ្ឍនភាពនៃការវាយតម្លៃជូនគណៈកម្មធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និងគណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការវាយតម្លៃ
- រៀបចំគម្រោងថវិកាសម្រាប់អនុវត្តការវាយតម្លៃ

- ចូលរួមនៅក្នុងកិច្ចប្រជុំ ឬសន្និបាត (ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ) ទាក់ទងនឹងការវាយតម្លៃ
- ស្នើ និង/ឬចូលរួមនៅក្នុងការបង្កើត និង/ឬការរំលាយ អនុគណៈកម្មាធិការ/កម្មការ/ក្រុមជាមួយគណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ និងគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស ក្នុងករណីចាំបាច់
- អភិវឌ្ឍសមត្ថភាពរបស់ខ្លួនទាក់ទងនឹងការវាយតម្លៃជាប្រចាំ
- កែលម្អដំណើរការវាយតម្លៃ
- ស្នើសុំឱ្យមានកិច្ចប្រជុំ ក្នុងករណីចាំបាច់
- អនុវត្តរាល់ភារកិច្ចទាំងអស់ ដែលប្រគល់ឱ្យដោយគណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និង/ឬ គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ

## ៤.២. តួនាទីរបស់នាយកដ្ឋានក្នុងការអភិវឌ្ឍសៀវភៅណែនាំ និងគោលការណ៍ណែនាំការវាយតម្លៃ

**<u>គោលការណ៍ទី2៖</u> នាយកដ្ឋានដឹកនាំត្រូវអភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំផ្សេងៗសម្រាប់ការវាយតម្លៃដែលខ្លួនគ្រប់គ្រង ហើយប្រើប្រាស់សៀវភៅណែនាំ ឬគោលការណ៍ទាំងនោះឱ្យមានប្រសិទ្ធភាពអំឡុងពេលអនុវត្តការវាយតម្លៃ។**

ដើម្បីធានាឱ្យបាននូវការអនុវត្តការវាយតម្លៃនីមួយៗប្រកបដោយប្រសិទ្ធភាព នាយកដ្ឋានដឹកនាំនីមួយៗត្រូវរៀបចំបង្កើតនូវសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំផ្សេងៗឱ្យបានច្បាស់លាស់សម្រាប់ការវាយតម្លៃដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រសិនបើគ្មានសៀវភៅណែនាំ ឬគោលការណ៍ណែនាំទេ នោះការអនុវត្តការវាយតម្លៃទាំងអស់ប្រាកដជាមិនអាចប្រព្រឹត្តទៅដោយភាពត្រឹមត្រូវនេះទេ។

រាល់សៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំទាំងអស់គួរមានបញ្ចូលនូវ គោលបំណង និងវត្ថុបំណងរបស់ការវាយតម្លៃ វិសាលភាព ព័ត៌មានស្ដីពីការបង្កើតសំណួរតេស្ត/ឧបករណ៍ របៀបអនុវត្តឬដំណើរការនៃការវាយតម្លៃ ការវិភាគទិន្នន័យ និងការប្រើប្រាស់លទ្ធផលដែលទទួលបាន។

### ៤.២.១. នាយកដ្ឋានធានាគុណភាពអប់រំ (EQAD)

EQAD គឺជានាយកដ្ឋានជំនាញផ្នែកវាយតម្លៃដែលស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។ EQAD ទទួលខុសត្រូវក្នុងការដឹកនាំតេស្តវង្វាយតម្លៃកម្រិតអន្តរជាតិ (PISA) តេស្តវង្វាយតម្លៃថ្នាក់តំបន់ (SEA-PLM) និងតេស្តវង្វាយតម្លៃថ្នាក់ជាតិ (ថ្នាក់ទី៣ ទី៦ ទី៨ និង ទី១១)។ ដោយហេតុនេះ EQAD មានទំនួលខុសត្រូវដូចខាងក្រោម៖

- បង្កើតសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃខាងក្រោមនេះ៖
  - តេស្តវង្វាយតម្លៃកម្រិតអន្តរជាតិ PISA
  - តេស្តវង្វាយតម្លៃថ្នាក់តំបន់ SEA-PLM
  - តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និង ទី១១
  - តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង
  - តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង
- ស្នើរៀបចំ និងបង្កើតគណៈកម្មាធិការគ្រប់គ្រង និងដឹកនាំ គណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស ដើម្បីអនុវត្តការវាយតម្លៃទាំងអស់នេះ
- គាំទ្រក្រុមបច្ចេកទេសក្នុងការ៖
  - អនុវត្តការវាយតម្លៃ
  - ធ្វើរបាយការណ៍
  - ផ្សព្វផ្សាយលទ្ធផល
  - សម្របសម្រួលផ្នែកហិរញ្ញវត្ថុ និងដំណើរការថវិកា
- ធ្វើការស្រាវជ្រាវដែលចាំបាច់ ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលនៃការវាយតម្លៃទាំងនេះ
- ចែករំលែកបទពិសោធន៍ទាក់ទងនឹងការវាយតម្លៃជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ទៅតាមភាពចាំបាច់

### ៤.២.២. នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD)

DCD គឺជានាយកដ្ឋានជំនាញផ្នែកកម្មវិធីសិក្សាស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។ DCD ទទួលខុសត្រូវលើការដឹកនាំការវាយតម្លៃមួយចំនួននៅថ្នាក់រៀន។ ដូច្នេះ នាយកដ្ឋាននេះមានទំនួលខុសត្រូវជាក់លាក់ដូចខាងក្រោមនេះ៖

- ធ្វើការជាមួយនឹង PED និង GSED ដើម្បីអភិវឌ្ឍសៀវភៅណែនាំ និង/គោលការណ៍ណែនាំដែលច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការប្រឡងប្រចាំខែ និងប្រចាំឆមាសក្នុងអំឡុងពេលសិក្សា ដែលធ្វើឡើងនៅកម្រិតថ្នាក់រៀន
- ជួយសម្របសម្រួលដល់ការបង្កើតក្រុមបច្ចេកទេស សម្រាប់អនុវត្តការវាយតម្លៃទាំងនេះ
- បណ្តុះបណ្តាល និងណែនាំក្រុមបច្ចេកទេសឱ្យអនុវត្តការវាយតម្លៃទាំងអស់នេះ ដោយគោរពតាមសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលបានបង្កើតឡើង
- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផល ដែលទទួលបានពីការវាយតម្លៃទាំងនេះ ដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្ស
- យកលទ្ធផលដែលទទួលបានពីការវាយតម្លៃផ្សេងៗរបស់នាយកដ្ឋានបច្ចេកទេសដទៃទៀតមកធ្វើជាភស្តុតាងដើម្បីកែលម្អកម្មវិធីសិក្សា ក៏ដូចជាការបង្រៀន និងរៀនរបស់សិស្ស

- គាំទ្រដល់ក្រុមបច្ចេកទេស ដើម្បីធ្វើរបាយការណ៍នានាអំពីការវាយតម្លៃទាំងនេះ
- ធ្វើការជាមួយនឹងនាយកដ្ឋានបច្ចេកទេសដទៃទៀត ដើម្បីអនុវត្តការវាយតម្លៃផ្សេងៗទៀត ទៅតាមភាពចាំបាច់
- ធ្វើការស្រាវជ្រាវដែលពាក់ព័ន្ធ ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលនៃការវាយតម្លៃទាំងនេះ
- ចែករំលែកបទពិសោធន៍ទាក់ទងនឹងការវាយតម្លៃជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ទៅតាមភាពចាំបាច់

### ៤.២.៣. នាយកដ្ឋានកិច្ចការប្រឡង (DEA)

DEA គឺជានាយកដ្ឋានជំនាញផ្នែកប្រឡងស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។ DEA ទទួលខុសត្រូវលើការដឹកនាំការប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២។ ដូច្នេះ នាយកដ្ឋាននេះមានទំនួលខុសត្រូវដូចខាងក្រោម៖

- អភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២
- សម្របសម្រួលបង្កើត គណៈកម្មាធិការគ្រប់គ្រង និងដឹកនាំ គណៈកម្មាធិការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស(ដោយគោរពតាមការណែនាំស្ដីពីការបង្កើតគណៈកម្មាធិការខាងលើ) ដើម្បីអនុវត្តការវាយតម្លៃទាំងអស់នេះ ដោយគោរពតាមសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលបានបង្កើតឡើង
- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃនេះដើម្បីកែលម្អការបង្រៀន និងរៀនរបស់សិស្ស
- រៀនសូត្រពីនាយកដ្ឋានបច្ចេកទេសដទៃទៀត ដើម្បីកែលម្អការរៀបចំការប្រឡង ក៏ដូចជាកែលម្អការបង្រៀន និងរៀនរបស់សិស្ស
- គាំទ្រដល់ក្រុមបច្ចេកទេសដើម្បីធ្វើរបាយការណ៍ផ្សេងៗអំពីការវាយតម្លៃនេះ
- គាំទ្រដល់ក្រុមបច្ចេកទេសចំពោះតម្រូវការផ្សេងៗ
- ចូលរួមជាមួយនឹងនាយកដ្ឋានបច្ចេកទេសផ្សេងៗដើម្បីអនុវត្តការវាយតម្លៃដទៃទៀត ក្នុងករណីចាំបាច់
- ធ្វើការស្រាវជ្រាវនានា ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលនៃការវាយតម្លៃនេះ
- ចែករំលែកបទពិសោធន៍ទាក់ទិននឹងការវាយតម្លៃជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ទៅតាមភាពចាំបាច់

### ៤.២.៤. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (GSED)

GSED គឺជានាយកដ្ឋានបច្ចេកទេសដែលស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា និងធ្វើការយ៉ាងជិតស្និទ្ធដើម្បីគាំទ្រដល់អនុវិទ្យាល័យ និងវិទ្យាល័យនៅកម្ពុជា។ GSED ទទួលខុសត្រូវក្នុងការអនុវត្តការវាយតម្លៃកម្រិតសាលារៀន និងថ្នាក់រៀនមួយចំនួនដូចជា ការប្រឡងឡើងថ្នាក់ ការ

ប្រឡងឆមាស និងការប្រឡងប្រចាំខែ នៅកម្រិតមធ្យមសិក្សា។ ដូច្នេះ នាយកដ្ឋាននេះមានទំនួលខុសត្រូវដូចខាងក្រោមនេះ៖

- អភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃដូចខាងក្រោម៖
  - ប្រឡងឡើងថ្នាក់ នៅកម្រិតមធ្យមសិក្សា
  - ប្រឡងឆមាស និងអំណានស្ទាត់នៅកម្រិតមធ្យមសិក្សា
  - ប្រឡងប្រចាំខែ នៅកម្រិតមធ្យមសិក្សា
- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលដែលបានមកពី ការវាយតម្លៃទាំងនេះ ដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្សនៅកម្រិតមធ្យមសិក្សា
- យកលទ្ធផលដែលបានមកពី PISA-D និង PISA ព្រមទាំងការវាយតម្លៃការសិក្សារបស់សិស្សនៅថ្នាក់ជាតិ (តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៨ និងទី១១) ជាភស្តុតាង ដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្ស នៅកម្រិតមធ្យមសិក្សា
- សម្របសម្រួលបង្កើត គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស (ដោយគោរពតាមការណែនាំស្តីពីការបង្កើតគណៈកម្មាធិការទាំងនេះខាងលើ) ដើម្បីអនុវត្តការវាយតម្លៃទាំងអស់នេះ ដោយគោរពតាមសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលបានបង្កើតឡើង
- ចូលរួមជាមួយនឹងនាយកដ្ឋានបច្ចេកទេសផ្សេងៗដើម្បីអនុវត្តការវាយតម្លៃដទៃទៀត ក្នុងករណីចាំបាច់
- ធ្វើការស្រាវជ្រាវនានា ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលនៃការវាយតម្លៃទាំងនេះ
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ ប្រសិនបើចាំបាច់

### ៤.២.៥. នាយកដ្ឋានបឋមសិក្សា (PED)

PED គឺជានាយកដ្ឋានជំនាញស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើការយ៉ាងជិតស្និទ្ធដើម្បីកែលម្អគុណភាពនៃការអប់រំនៅកម្រិតបឋមសិក្សា។ PED ទទួលខុសត្រូវលើការដឹកនាំអនុវត្ត និងការវាយតម្លៃកម្រិតសាលារៀន និងថ្នាក់រៀនមួយចំនួនដូចជា ការប្រឡងឡើងថ្នាក់ ការប្រឡងឆមាស និងអំណានស្ទាត់ និងការប្រឡងប្រចាំខែ នៅកម្រិតបឋមសិក្សា។ ទន្ទឹមនឹងនេះ PED ទទួលខុសត្រូវក្នុងការអនុវត្តការវាយតម្លៃលើការត្រៀមលក្ខណៈចូលសាលានៅថ្នាក់ទី១ផងដែរ។ ដូច្នេះ PED មានទំនួលខុសត្រូវដូចខាងក្រោម៖

- អភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃដូចខាងក្រោម៖
  - ប្រឡងឡើងថ្នាក់ នៅកម្រិតបឋមសិក្សា
  - ប្រឡងប្រចាំខែ នៅកម្រិតបឋមសិក្សា
  - ប្រឡងឆមាសនិង អំណានស្ទាត់ នៅកម្រិតបឋមសិក្សា

- ធ្វើការជាមួយនឹងនាយកដ្ឋានកុមារតូច(ECED) ដើម្បីអភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃលើការត្រៀមលក្ខណៈចូលសាលារបស់កុមារ
- សម្របសម្រួលបង្កើត គណៈកម្មាធិការ/កម្មការគ្រប់គ្រង និងដឹកនាំ គណៈកម្មាធិការ/កម្មការតាមដាន និងគាំទ្របច្ចេកទេស និងក្រុមបច្ចេកទេស(ដោយគោរពតាមការណែនាំស្ដីពីការបង្កើតគណៈកម្មាធិការទាំងនេះខាងលើ) ដើម្បីអនុវត្តការវាយតម្លៃទាំងអស់នេះ ដោយគោរពតាមសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលបានបង្កើតឡើង
- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃទាំងនេះដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្ស
- រៀនសូត្រពីលទ្ធផលដែលបានមកតេស្តវង្វាយតម្លៃ PISA-D, PISA, SEA-PLM ការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ (តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ និងទី៦) តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង និងតេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង ធ្វើជាភស្តុតាងដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្ស ក៏ដូចជា អន្តរាគមន៍ផ្សេងៗរបស់កម្មវិធីលើកកម្ពស់អំណានថ្នាក់ដំបូង និងកម្មវិធីលើកកម្ពស់គណិតវិទ្យាថ្នាក់ដំបូង នៅកម្រិតបឋមសិក្សា
- ធ្វើការជាមួយនឹងនាយកដ្ឋានបច្ចេកទេសផ្សេងៗ ដើម្បីអនុវត្តការវាយតម្លៃដទៃទៀត តាមភាពចាំបាច់
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ
- គាំទ្រក្រុមបច្ចេកទេស ដើម្បីធ្វើរបាយការណ៍អំពីការវាយតម្លៃលើការត្រៀមលក្ខណៈចូលសាលារបស់កុមារ
- ធ្វើការស្រាវជ្រាវដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលនៃការវាយតម្លៃទាំងនេះ

### ៤.២.៦. នាយកដ្ឋានអប់រំកុមារតូច (ECED)

ECED គឺជានាយកដ្ឋានជំនាញដែលស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយមត្តេយ្យសិក្សាដើម្បីអភិវឌ្ឍការអប់រំនៅប្រទេសកម្ពុជា។ ECED ទទួលខុសត្រូវលើការដឹកនាំការវាយតម្លៃនៅកម្រិតមត្តេយ្យសិក្សា/ការត្រៀមលក្ខណៈចូលសាលារបស់កុមារ។ ដូច្នេះ ECED មានទំនួលខុសត្រូវដូចខាងក្រោម៖

- អភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃថ្នាក់មត្តេយ្យ
- ធ្វើការជាមួយ PED ដើម្បីបង្កើតសៀវភៅណែនាំ/គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃលើការត្រៀមលក្ខណៈចូលសាលារបស់សិស្ស
- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃទាំងនេះដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្សនៅកម្រិតមត្តេយ្យសិក្សា

- រៀនសូត្រពីលទ្ធផលដែលបានមកតេស្តវង្វាយតម្លៃ PISA-D, PISA, SEA-PLM ការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង និងតេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង ធ្វើជាភស្តុតាងដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្ស នៅកម្រិតមត្តេយ្យសិក្សា
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ ប្រសិនបើចាំបាច់

### ៩.២.៧. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ (TTD)

TTD គឺជានាយកដ្ឋានបច្ចេកទេសស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋាននេះ ធ្វើការយ៉ាងជិតស្និទ្ធដើម្បីផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀន (វិក្រិតការគ្រូបង្រៀន) ក៏ដូចជាគាំទ្រដល់គ្រឹះស្ថានបណ្តុះបណ្តាលនិងវិក្រឹត្យការនានានៅក្នុងប្រទេសកម្ពុជាផងដែរ។ ដូច្នេះ TTD មានទំនួលខុសត្រូវដូចខាងក្រោម៖

- ជួយគាំទ្រដល់នាយកដ្ឋានដឹកនាំក្នុងការអភិវឌ្ឍ និង/ឬ ត្រួតពិនិត្យឡើងវិញលើសៀវភៅណែនាំ/គោលការណ៍ណែនាំនានា
- ដឹកនាំការអភិវឌ្ឍគោលការណ៍ណែនាំស្តីពីការវាយតម្លៃតាមដំណាក់ សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន ក៏ដូចជាសម្រាប់គ្រូបង្រៀនយកទៅប្រើអំឡុងពេលបង្រៀនផងដែរ
- យកលទ្ធផលដែលបានមកពី PISA-D, PISA, SEA-PLM ព្រមទាំងការវាយតម្លៃការសិក្សារបស់សិស្សនៅថ្នាក់ជាតិ ដើម្បីកែលម្អការបណ្តុះបណ្តាលគ្រូបង្រៀន និងការធ្វើវិក្រិតការគ្រូបង្រៀនគ្រប់រូបភាព
- ដាក់បញ្ចូលព័ត៌មានដែលបានមកពីសៀវភៅណែនាំ/គោលការណ៍ណែនាំផ្សេងៗ ក៏ដូចជាមតិត្រលប់របស់សាលាទៅក្នុងការបណ្តុះបណ្តាលគ្រូ និងការធ្វើវិក្រិតការគ្រូបង្រៀន
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ ក្នុងករណីចាំបាច់

### ៩.២.៨. នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ (EMIS)

EMIS គឺជានាយកដ្ឋានដែលស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសត្រូវក្នុងការប្រមូលព័ត៌មាននានា (ឧទាហរណ៍ ពិន្ទុឆមាស អត្រាបោះបង់ការសិក្សា អត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់។ល។) ពីសាលារៀនទាំងអស់នៅកម្ពុជា ក៏ដូចជាគ្រប់គ្រង និងរក្សាទុកទិន្នន័យសម្រាប់ក្រសួងអប់រំ យុវជន និងកីឡាទាំងមូលផងដែរ។ ដូច្នេះ EMIS មានទំនួលខុសត្រូវដូចខាងក្រោម៖

- ជួយគាំទ្រដល់នាយកដ្ឋានដឹកនាំផ្សេងៗក្នុងការអភិវឌ្ឍ និង/ឬ ត្រួតពិនិត្យឡើងវិញលើសៀវភៅណែនាំ/គោលការណ៍ណែនាំនានា
- ជួយពង្រឹងដំណើរការនៃការអនុវត្តការវាយតម្លៃផ្សេងៗ ដើម្បីទទួលបានទិន្នន័យកាន់តែសុក្រឹត
- សិក្សាពីលទ្ធផលរបស់ការវាយតម្លៃទាំងអស់ ដើម្បីកែលម្អប្រព័ន្ធព័ត៌មានឱ្យកាន់តែអាចមានភាពជឿជាក់ខ្ពស់
- ធ្វើការជាមួយនឹងនាយកដ្ឋានបច្ចេកទេសផ្សេងៗដើម្បីអនុវត្តការវាយតម្លៃដទៃទៀត តាមភាពចាំបាច់

- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ

### ៤.២.៩. នាយកដ្ឋានអប់រំពិសេស (SED)

SED គឺជានាយកដ្ឋានជំនាញបច្ចេកទេសដែលស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយថ្នាក់ក្រោមជាតិដើម្បីជួយគាំទ្រដល់សិស្សពិការ និងសិស្សមានតម្រូវការពិសេសក្នុងពេលអប់រំ (ទាំងនៅសាលារដ្ឋ និងសាលារបស់អង្គការមិនមែនរដ្ឋាភិបាល) នៅកម្ពុជា។ SED មានទំនួលខុសត្រូវដូចខាងក្រោម៖

- អភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំដែលច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់បញ្ជីត្រួតពិនិត្យពិការភាពរបស់សិស្ស បើទោះជាមិនបានបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃការវាយតម្លៃនេះក្តី
- គាំទ្រដល់នាយកដ្ឋានដឹកនាំនានា ដើម្បីអភិវឌ្ឍសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំផ្សេងៗដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃកម្រិតថ្នាក់រៀនក្នុងករណីចាំបាច់
- សិក្សាពីលទ្ធផលរបស់ការវាយតម្លៃទាំងអស់ដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្សពិការ និងសិស្សដែលមានតម្រូវការពិសេសក្នុងពេលអប់រំ
- ជួយដល់នាយកដ្ឋានបច្ចេកទេសក្នុងការអនុវត្តការវាយតម្លៃផ្សេងៗ ក្នុងករណីចាំបាច់
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ

### ៤.២.១០. នាយកដ្ឋានគោលនយោបាយ (DPo)

DPo គឺជានាយកដ្ឋានជំនាញផ្នែកគោលនយោបាយដែលស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋាននេះ មានភារៈកិច្ចក្នុងការអភិវឌ្ឍគោលនយោបាយថ្មីៗសម្រាប់វិស័យអប់រំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ DPo ក៏មានតួនាទី ពិនិត្យតាមដាន និងវាយតម្លៃលើគោលនយោបាយដែលមានស្រាប់ និងកំពុងត្រូវបានអនុវត្តក្នុងពេលបច្ចុប្បន្នផងដែរ។ ដូច្នេះ នាយកដ្ឋាននេះមានទំនួលខុសត្រូវជាក់លាក់ដូចខាងក្រោម៖

- ជួយគាំទ្រដល់នាយកដ្ឋានដឹកនាំនានាក្នុងការអភិវឌ្ឍសៀវភៅណែនាំ និងគោលការណ៍ណែនាំផ្សេងៗដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ការវាយតម្លៃទាំងអស់
- សិក្សា និងប្រើប្រាស់លទ្ធផលដែលទទួលបានពីការវាយតម្លៃទាំងអស់ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃលើគោលនយោបាយដែលមានស្រាប់ ក៏ដូចជាដើម្បីអភិវឌ្ឍគោលនយោបាយថ្មីៗ
- ធ្វើការស្រាវជ្រាវ(តាមបែបគុណវិស័យ)បន្ថែមដើម្បីបញ្ជាក់ទៅលើលទ្ធផលដែលរកឃើញរបស់តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងកម្រិតអន្តរជាតិផ្សេងៗ ក្នុងករណីចាំបាច់
- ធ្វើការជាមួយនឹងនាយកដ្ឋានបច្ចេកទេសផ្សេងទៀតដើម្បីអនុវត្តការវាយតម្លៃផ្សេងៗ តាមភាពចាំបាច់
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ ក្នុងករណីចាំបាច់

### ៤.២.១១. ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល

ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តការវាយតម្លៃទាំងនេះក្នុងពេលបច្ចុប្បន្ន។ ដូចនេះ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលមានតួនាទីជាក់លាក់ដូចខាងក្រោមនេះៈ

- ជួយគាំទ្រ (ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស) សម្រាប់ការអនុវត្តការវាយតម្លៃទាំងនេះ
- ជួយគាំទ្រ (ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស) ក្នុងការផលិតសៀវភៅណែនាំ គោលការណ៍ណែនាំ និងឧត្តមានុវត្តន៍
- ប្រើប្រាស់ និងគោរពតាមសៀវភៅណែនាំ និង/ឬគោលការណ៍ណែនាំរបស់ការវាយតម្លៃ ដែលមានស្រាប់
- ចែករំលែកបទពិសោធន៍ដើម្បីកែលម្អការវាយតម្លៃ ក្នុងករណីចាំបាច់

## ៤.៣. ការប្រើប្រាស់ និងការកែលម្អការវាយតម្លៃ

**<u>គោលការណ៍ទី៣៖</u> ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើការជាមួយគ្នាដើម្បីអនុវត្ត និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវលទ្ធផលរបស់ការវាយតម្លៃ។ នាយកដ្ឋានដឹកនាំ និង/ឬ ក្រុមប្រតិបត្តិគួរធ្វើការវាយតម្លៃ (ស្វ័យវាយតម្លៃ ឬការវាយតម្លៃពីខាងក្រៅ) ឱ្យបានជាប្រចាំ ដើម្បីធ្វើការកែលម្អដំណើរការ និងគុណភាពនៃការវាយតម្លៃ ទៅតាមភាពចាំបាច់។**

### ៤.៣.១. ថ្នាក់ជាតិ

ដូចបានរៀបរាប់ខាងលើ ការវាយតម្លៃផ្ទៃក្រៅ រួមមាន តេស្តវង្វាយតម្លៃកម្រិតអន្តរជាតិ PISA តេស្តវង្វាយតម្លៃការសិក្សាសម្រាប់សិស្សបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) តេស្តវង្វាយតម្លៃសិស្សថ្នាក់ជាតិ (ថ្នាក់ទី៣ ទី៦ ទី៨ និង ទី១១) តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង និងការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ គឺជាគំនិតផ្តួចផ្តើមពីថ្នាក់ជាតិ។ ដូច្នេះ ភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ ជាពិសេសនាយកដ្ឋានដឹកនាំ ត្រូវអនុវត្តការវាយតម្លៃទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់តាម រយៈការធ្វើការជាមួយនឹងថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធទាំងអស់។ នាយកដ្ឋានដឹកនាំ ត្រូវផ្សព្វផ្សាយលទ្ធផលដល់ភាគីពាក់ព័ន្ធ ហើយប្រើប្រាស់លទ្ធផលទាំងនោះដើម្បីជាមធ្យោបាយក្នុងការកែលម្អគុណភាពអប់រំនៅកម្ពុជា។ នាយកដ្ឋានដឹកនាំ និង/ឬក្រុមប្រតិបត្តិ គួរធ្វើស្វ័យវាយតម្លៃ និង/ឬការវាយតម្លៃជាលក្ខណៈផ្ទៃក្នុងឱ្យបានជាប្រចាំដើម្បីទទួលបាននូវព័ត៌មានត្រឡប់ ឬយោបល់ល្អៗជុំវិញដំណើរការ ក៏ដូចជាគុណភាពនៃការវាយតម្លៃ ហើយបន្ទាប់មកធ្វើការកែលម្អទៅតាមភាពចាំបាច់។

### ៤.៣.២. ថ្នាក់ក្រោមជាតិ

ការវាយតម្លៃកម្រិតសាលារៀន និងកម្រិតថ្នាក់រៀន ត្រូវបានអនុវត្តដោយថ្នាក់ក្រោមជាតិ (ថ្នាក់រាជធានី/ខេត្ត ស្រុក និងនៅសាលារៀន) ។ ដូច្នេះ គ្រប់គ្នាត្រូវអនុវត្តការវាយតម្លៃទាំងនេះឱ្យមានប្រសិទ្

ភាពខ្ពស់ ហើយប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃទាំងនេះ ដើម្បីកែលម្អការបង្រៀន និងការរៀនរបស់សិស្សនៅថ្នាក់ក្រោមជាតិ។ នៅពេលចាំបាច់ ថ្នាក់ក្រោមជាតិគួរសុំការគាំទ្រពីថ្នាក់ជាតិ។ ក្រុមប្រតិបត្តិគួរធ្វើស្វ័យវាយតម្លៃ និង/ឬការវាយតម្លៃជាលក្ខណៈផ្ទៃក្នុងឱ្យបានជាប្រចាំដើម្បីទទួលបាននូវព័ត៌មានត្រលប់ ឬយោបល់ល្អៗជុំវិញដំណើរការ ក៏ដូចជាគុណភាពនៃការវាយតម្លៃ ហើយបន្ទាប់មកធ្វើការកែលម្អទៅតាមភាពចាំបាច់។

- ***សាលារៀន***

សាលារៀនជាគ្រឹះស្ថានអនុវត្តជាក់ស្តែង។ សាលារៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាគុណភាពការអប់រំ។ ដូច្នេះ ចំពោះការវាយតម្លៃ សាលារៀននីមួយៗមានតួនាទីជាក់លាក់ដូចខាងក្រោម៖

  - អនុវត្តរាល់ការវាយតម្លៃកម្រិតសាលារៀន និងថ្នាក់រៀនទាំងអស់ទៅតាមសៀវភៅណែនាំ/គោលការណ៍ណែនាំដែលមានកំណត់
  - ធ្វើការជាមួយនឹងថ្នាក់ជាតិដើម្បីអនុវត្តការវាយតម្លៃផ្ទៃក្រៅ
  - ប្រើប្រាស់លទ្ធផល និងការរកឃើញនានា ដើម្បីកែលម្អគ្រឹះស្ថានរបស់ខ្លួន ជាពិសេសសម្រាប់ការអភិវឌ្ឍការសិក្សារបស់សិស្សនៅក្នុងថ្នាក់

- ***ការិយាល័យអប់រំស្រុក (DoE)***

ស្រុកធ្វើការជិតស្និទ្ធជាមួយនឹងសាលារៀន ដើម្បីធានាឱ្យបាននូវគុណភាពអប់រំ។ ដូច្នេះ ចំពោះការងារវាយតម្លៃ ការិយាល័យអប់រំស្រុកនីមួយៗ មានតួនាទីជាក់លាក់ដូចខាងក្រោម៖

  - ជួយគាំទ្រដល់សាលារៀន ដើម្បីអនុវត្តរាល់ការវាយតម្លៃកម្រិតសាលារៀន និងកម្រិតថ្នាក់រៀន ទៅតាមសៀវភៅណែនាំ/គោលការណ៍ណែនាំដែលបានកំណត់
  - ត្រូវធានាថា គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល និងការគាំទ្រគ្រប់គ្រាន់ សម្រាប់អនុវត្តការវាយតម្លៃ និងប្រើប្រាស់លទ្ធផលនៃការវាយតម្លៃទាំងអស់
  - ពិនិត្យតាមដាន និងធានាឱ្យបាននូវគុណភាពខ្ពស់នៃការវាយតម្លៃ
  - ប្រើប្រាស់លទ្ធផល និងការរកឃើញនានា ដើម្បីកែលម្អការបង្រៀន និងការរៀននៅក្នុងស្រុករបស់ខ្លួន
  - ធ្វើការជាមួយនឹងថ្នាក់ជាតិដើម្បីអនុវត្តការវាយតម្លៃផ្ទៃក្រៅផ្សេងៗទៀត

- ***មន្ទីរអប់រំ យុវជន និងកីឡា រាជធានី/ខេត្ត (PoE)***

មន្ទីរអប់រំយុវជន និងកីឡារាជធានី/ខេត្តធ្វើការជិតស្និទ្ធជាមួយនឹងការិយាល័យអប់រំស្រុក និងសាលារៀន ដើម្បីធានានូវគុណភាពអប់រំ។ ដូច្នេះ ចំពោះការវាយតម្លៃ គ្រប់មន្ទីរអប់រំរាជធានី/ខេត្តនីមួយៗ មានតួនាទីជាក់លាក់ដូចខាងក្រោម៖

  - ជួយគាំទ្រដល់ការិយាល័យអប់រំស្រុក និងសាលារៀន ក្នុងការអនុវត្តការវាយតម្លៃនៅថ្នាក់រៀនទាំងអស់ ទៅតាមសៀវភៅណែនាំ/គោលការណ៍ណែនាំដែលបានកំណត់
  - ពិនិត្យតាមដាន និងធានាឱ្យបាននូវគុណភាពខ្ពស់នៃការវាយតម្លៃ

- ប្រើប្រាស់លទ្ធផល និងការរកឃើញនានា ដើម្បីកែលម្អការបង្រៀន និងការរៀននៅក្នុងខេត្តរបស់ខ្លួន
- ធ្វើការជាមួយនឹងថ្នាក់ជាតិដើម្បីអនុវត្តការវាយតម្លៃផ្ទៃក្រៅ

# ឯកសារយោង


Anderson, Prue, and George Morgan. 2008. *Developing Tests and Questionnaires for a National Assessment of Educational Achievement*. Series Edition. Vol. 2. Washington, DC: The World Bank.

LEARNING ASSESSMENT COMMITTEE. 2017. “Student Learning Outcomes Assessment Framework and Guidelines.” TULSA COMMUNITY COLLEGE.

Ministry of Education, Youth and Sport (MoEYS). 2013. “បញ្ញត្តិនៃការធានាគុណភាពអប់រំ និងអប់រំចំណេះទូទៅនៅកម្ពុជា៖ អធិការកិច្ច.” EQAD.

———. 2014. “Education Strategic Plan 2014-2018.” Strategic Plan for the Ministry. Phnom Penh: MOEYS.

———. 2015. “Results of Grade Six Student Achievement from the National Assessment in 2013.” Phnom Penh: EQAD.

———. 2016a. *CURRICULUM FRAMEWORK OF GENERAL EDUCATION AND TECHNICAL EDUCATION*. Phnom Penh: DCD.

———. 2016b. “Results of Grade Three Student Achievement from the National Assessment in 2015.” Phnom Penh: EQAD.

———. 2017a. “Results of Grade Six Student Achievement from the National Assessment in 2016.” Phnom Penh: EQAD.

———. 2017b. “ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល៖ ការងារអធិការកិច្ចសាលារៀន ផ្ដោតលើបច្ចេកទេសរៀន និងបង្រៀនសម្រាប់បឋមសិក្សា.” EQAD.

———. 2018. “Results of Grade 8 Student Achievement from the National Assessment in 2017.” Grade 8 National Student Learning Assessment. EQAD.

OECD. 2009. “Evaluation and Assessment Frameworks for Improving School Outcomes: Common Policy Challenges.” Education and Training Policy. OECD.

Save the Children. 2015. “ការពិនិត្យតាម និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅបឋមសិក្សា.” Save the Children.

UNESCO. 2017a. “Analyzing and Utilizing Assessment Data for Better Learning Outcomes.” Bangkok: NEQMAP.

———. 2017b. “Principles of Good Practice in Learning Assessment.” The Manual of Good Practice in Learning Assessment. UNESCO Institute of Statistics.

Varnet, Harvey, and Martha Rice Sanders. 2004. “Asking Better Questions: Small-Scale Assessment Measures That Inform Ongoing Work.” *The Phillips Memorial Library*, no. 3 (December).